# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិ

# មូលនិធិសម្រាប់ផ្តល់សេវា

## គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល

*ថ្ងៃទី២៤ ខែ វិច្ឆិកា ឆ្នាំ២០១៦*

*ក្រសួងសុខាភិបាល*

*អាគារលេខ៨០ មហាវិថី សម្តេច ប៉ែន នុត (ផ្លូវលេខ២៨៩) ខ័ណ្ឌទួលគោក*

*រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*

# តារាងពាក្យបំព្រួញ

| | |
|---|---|
| AOP | ផែនការប្រតិបត្តិប្រចាំឆ្នាំ<br>Annual Operational Plan |
| BETF | មូលនិធិត្រាស់ហ្វាន់គ្រប់គ្រងដោយធនាគារ<br>Bank-executed Trust Fund |
| BSC | តារាងដាក់ពិន្ទុវាយតម្លៃ<br>Balance Score Card |
| BSP | ផែនការយុទ្ធសាស្ត្រថវិកា<br>Budget Strategic Plan |
| CBHI | កម្មវិធីធានារ៉ាប់រងសុខភាពសហគមន៍<br>Community Based Health Insurance |
| CC | ក្រុមប្រឹក្សាឃុំ<br>Commune Council |
| CDHS | ការអង្កេតប្រជាសាស្ត្រ និង សុខភាព កម្ពុជា<br>Cambodia Demographic and Health Survey |
| CPA | សំណុំសកម្មភាពបង្គ្រប់<br>Complementary Package of Activities |
| CSC | តារាងពិន្ទុវាយតម្លៃដោយសហគមន៍<br>Community Score Card |
| DBF | នាយកដ្ឋានថវិកា និង ហិរញ្ញវត្ថុ<br>Department of Budget and Finance |
| D&D | វិមជ្ឈការ និង វិសហមជ្ឈការ<br>Decentralization & Deconcentration |
| DFAT | នាយកដ្ឋានកិច្ចការបរទេស និង ពាណិជ្ជកម្ម<br>Department of Foreign Affairs and Trade |

| | |
|---|---|
| DIC | នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| | Department of International Cooperation |
| DLI | ការទូទាត់ផ្សារភ្ជាប់នឹងសូចនាករ |
| | Disbursement Linked Indicator |
| DHDC | គណៈកម្មការអភិវឌ្ឍន៍សុខាភិបាលស្រុក |
| | District Health Development Committee |
| DHFSC | គណៈកម្មការសម្របសម្រួលហិរញ្ញប្បទានសុខាភិបាលស្រុក |
| | District Health Financing Steering Committee |
| DGAF | អគ្គនាយក រដ្ឋបាល និង ហិរញ្ញវត្ថុ |
| | Director General for Administration and Finance |
| DHS | នាយកដ្ឋានសេវាមន្ទីរពេទ្យ |
| | Department Hospital Services, HSD |
| DIA | នាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| | Department of Internal Audit, IAD |
| DP | ដៃគូអភិវឌ្ឍន៍ |
| | Development Partner |
| | នាយកដ្ឋានបុគ្គលិក |
| | Department of Personnel |
| DPHI | នាយកដ្ឋានផែនការ និង ព័ត៌មានសុខាភិបាល |
| | Department of Planning and Health Information |
| EEP | កម្មវិធីចំណាយដែលអាចចាយបាន |
| | Eligible Expenditure Program |
| EMF | ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន |
| | Environmental Management Framework |
| EMP | ផែនការគ្រប់គ្រងបរិស្ថាន |
| | Environmental Management Plan |

| | | |
|---|---|---|
| FM | ការគ្រប់គ្រងហិរញ្ញវត្ថុ | Financial Management |
| FMM | នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោង | Financial Management Manual |
| FY | ឆ្នាំសារពើពន្ធ | Fiscal Year |
| GIZ | ទីភ្នាក់ងារអាល្លឺម៉ង់ដើម្បីកិច្ចសហប្រតិបត្តិការអន្តរជាតិ | German Agency for International Cooperation |
| GDNT | អគ្គនាយកដ្ឋានរតនាគារជាតិ | General Department of the National Treasury |
| HC | មណ្ឌលសុខភាព | Health Center |
| HCF | មូលដ្ឋានសុខាភិបាល | Health Care Facility |
| HCWM | ការគ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រ | Health Care Waste Management |
| HCWMP | ផែនការគ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រ | Health Care Waste Management Plan |
| HEF | មូលនិធិសមធម៌ | Health Equity Fund |
| HEFI | ប្រតិបត្តិករមូលនិធិសមធម៌ | Health Equity Fund Implementer |
| H-EQIP | គម្រោងលើកកម្ពស់គុណភាព និង សមធម៌សុខាភិបាល | Health Equity and Quality Improvement Project |
| HIS | ប្រព័ន្ធព័ត៌មានសុខាភិបាល | Health Information System |

HMIS ប្រព័ន្ធព័ត៌មានគ្រប់គ្រងសុខាភិបាល

Health Management Information System

HP ដៃគូសុខាភិបាល

Health Partner

ប៉ុស្តិ៍សុខភាព

Health Post

HR ធនធានមនុស្ស

Human Resources

HRMIS ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស

Human Resource Management Information System

HSD នាយកដ្ឋានមន្ទីរពេទ្យ

Hospital Service Department, DHS

HSP ផែនការយុទ្ធសាស្ត្រសុខាភិបាល

Health Strategic Plan

HSP-3 ផែនការយុទ្ធសាស្ត្រសុខាភិបាលដំណាក់កាលទី៣

Third Health Strategic Plan

IAD នាយកដ្ឋានសវនកម្មផ្ទៃក្នុង

Internal Audit Department

ICB ការដេញថ្លៃដោយប្រកួតប្រជែងថ្នាក់អន្តរជាតិ

International Competitive Bidding

ការកសាងសមត្ថភាពស្ថាប័ន

Institutional Capacity Building

ICT បច្ចេកវិទ្យា ព័ត៌មាន និង ទូរគមនាគមន៍

Information Communication Technology

IDA សមាគមន៍អភិវឌ្ឍន៍អន្តរជាតិ

International Development Association

| | | |
|---|---|---|
| INT | នាយកដ្ឋានសុច្ចរិតភាពស្ថាប័ន<br>Department of Institutional Integrity | |
| IPPF | ក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច<br>Indigenous People Planning Framework | |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន<br>Japan International Cooperation Agency | |
| KfW | ធនាគារអភិវឌ្ឍន៍នៃរដ្ឋាភិបាលអាល្លឺម៉ង់<br>German government-owned development bank (Kreditanstalt für Wiederaufbau) | |
| KOICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ<br>Korea International Cooperation Agency | |
| M&E | ការតាមដាន និង វាយតម្លៃ<br>Monitoring and Evaluation | |
| MDTF | មូលនិធិត្រាស់ហ្វាន់ពហុភាគី<br>Multi-donor Trust Fund | |
| MEF | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>Ministry of Economy and Finance | |
| MOH | ក្រសួងសុខាភិបាល<br>Ministry of Health | |
| MPA | សំណុំសកម្មភាពអប្បបរមា<br>Minimum Package of Activities | |
| NCD | ជំងឺមិនឆ្លង<br>Non-Communicable Disease | |
| NGO | អង្គការមិនមែនរដ្ឋាភិបាល<br>Nongovernmental Organization | |
| NQEMP | យន្តការជាតិតាមដានការកែលម្អគុណភាពសុខាភិបាល<br>National Quality Enhancement Monitoring Process | |

| | | |
|---|---|---|
| NQEMT | ឧបករណ៍តាមដានការកែលម្អគុណភាពសុខាភិបាលថ្នាក់ជាតិ | |
| | National Quality Enhancement Monitoring Tools | |
| OCA | ការវាយតម្លៃសមត្ថភាពស្ថាប័ន | |
| | Organizational Capacity Assessment | |
| OD | ស្រុកប្រតិបត្តិសុខាភិបាល | |
| | Operational District | |
| ODO | ការិយាល័យស្រុកប្រតិបត្តិសុខាភិបាល | |
| | Operational District Office | |
| OM | សេចក្តីណែនាំការអនុវត្តន៍ | |
| | Operational Manual | |
| OOP | ចំណាយប្រាក់ហោប៉ៅ | |
| | Out of Pocket | |
| OPD | ផ្នែកពិគ្រោះជំងឺក្រៅ | |
| | Outpatient Department | |
| PAE | សហគ្រាសរដ្ឋបាលសាធារណៈ | |
| | Public Administrative Establishment | |
| PCA | ភ្នាក់ងារផ្ទៀងផ្ទាត់ការទូទាត់ | |
| | Payment Certification Agency | |
| PDO | កម្មវត្ថុអភិវឌ្ឍន៍គម្រោង | |
| | Project Development Objective | |
| PFM | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | |
| | Public Financial Management | |
| PHD | មន្ទីរសុខាភិបាលខេត្ត | |
| | Provincial Health Department | |
| PHDO | ការិយាល័យមន្ទីរសុខាភិបាលខេត្ត | |
| | Provincial Health Department Office | |

| | |
|---|---|
| PMD | នាយកដ្ឋានការពារសុខភាព<br>Preventive Medicine Department |
| PMMP | ផែនការគ្រប់គ្រងនិងតាមដានបាណកសត្វ<br>Pest Management and Monitoring Plan |
| PRH | មន្ទីរពេទ្យបង្អែកខេត្ត<br>Provincial Referral Hospital |
| Pro-TWGH | ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្ត<br>Provincial Technical Working Group for Health |
| QAO | ការិយាល័យធានាគុណភាព<br>Quality Assurance Office |
| QOC | គុណភាពសេវាសុខាភិបាល<br>Quality of Care |
| RGC | រាជរដ្ឋាភិបាលកម្ពុជា<br>Royal Government of Cambodia |
| RH | មន្ទីរពេទ្យបង្អែក<br>Referral Hospital |
| SDG | មូលនិធិសម្រាប់ផ្តល់សេវា<br>Service Delivery Grant |
| SHP | គាំពារសុខភាពសង្គម<br>Social Health Protection |
| SOA | ទីភ្នាក់ងារប្រតិបត្តិការពិសេស<br>Special Operating Agency |
| SOP | និតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍<br>Standard Operating Procedure |
| TA | ជំនួយបច្ចេកទេស<br>Technical Assistance |

| | | |
|---|---|
| TF | មូលនិធិត្រាស់ហ្វាន់<br>Trust Fund |
| TOR | ការបរិយាយតម្រូវការសម្រាប់ការងារ<br>Terms of Reference |
| TSA | គណនីរតនាគារតែមួយ<br>Treasury Single Account |
| UHC | ការគ្របដណ្តប់សុខភាពជាសកល<br>Universal Health Coverage |
| UHS | សាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល<br>University of Health Sciences |
| UNFPA | មូលនិធិអង្គការសហប្រជាជាតិដើម្បីប្រជាជន<br>United Nations Population Fund |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ<br>United Nations Children´s Fund |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ<br>U.S. Agency for International Development |
| WHO | អង្គការសុខភាពពិភពលោក<br>World Health Organization |

## មាតិកា

អារម្ភកថា ..................................................................................................................... ១៦

១. បរិយាយអំពី មូលនិធិសម្រាប់ផ្តល់សេវា ............................................................................. ១៨

១.១ បរិយាយអំពីកញ្ចប់ថវិកាសម្រាប់ប្រតិបត្តការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល ............................................................................................................. ១៨

១.២ បរិយាយអំពី កញ្ចប់ថវិកាផ្អែកលើលទ្ធផលការងារ ................................................................ ១៩

១.៣ មូលនិធិសម្រាប់ផ្តល់សេវា និង យន្តការជាតិនៃការបង្កើនគុណភាព ............................................ ២០

១.៤ លក្ខណៈវិនិច្ឆ័យដើម្បីសម្រាប់ទទួលបាន ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ ....................................... ២១

២. ការរៀបចំស្ថាប័ន (រចនាសម្ព័ន្ធគ្រប់គ្រង) ............................................................................. ២២

២.១ តួនាទី និងការទទួលខុសត្រូវមានដូចតទៅ: ........................................................................ ២៣

៣. ការផ្ទៀងផ្ទាត់គុណភាពស្នាដៃការងារ .................................................................................. ២៦

៣.១ ភាពញឹកញាប់ ............................................................................................................. ២៧

៣.២ សមាសភាពក្រុមអ្នកវាយតម្លៃដែលមានវិញ្ញាបនប័ត្រ ............................................................. ៣១

មណ្ឌលសុខភាព៖ អ្នកវាយតម្លៃ២នាក់មកពីស្រុកប្រតិបត្តិ ............................................................. ៣១

៣.៣ ពេលវេលានៃការវាយតម្លៃ និងការបង្វឹក ........................................................................... ៣១

៣.៤ ការចងក្រងលទ្ធផល និងការផ្តល់សំណាង ............................................................................. ៣២

៣.៥ ការផ្តល់វិញ្ញាបនប័ត្រដល់អ្នកវាយតម្លៃដើម្បីពង្រឹងលទ្ធផល ........................................................ ៣២

៣.៦ ឧបករណ៍តាមដានកែលម្អគុណភាពថ្នាក់ជាតិ ....................................................................... ៣២

៣.៧ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) ......................................................................... ៣៤

៣.៨ សេចក្តីណែនាំប្រចាំឆ្នាំរបស់នាយកគ្រប់គ្រងគម្រោង ................................................................ ៣៥

៤. ការចំណាយដែលមានសិទ្ធិស្របច្បាប់ .................................................................................. ៣៥

៤.១ ប្រភេទចំណាយនៃមូលនិធិសម្រាប់ផ្តល់សេវាដែលស្របច្បាប់ ...................................................... ៣៦

៥. វិធានការរដ្ឋបាលត្រូវអនុវត្តសម្រាប់ការធ្វើរបាយការណ៍មិនត្រឹមត្រូវ ....................................៣៩
៥.១ របាយការណ៍មិនត្រឹមត្រូវ....................................................................................................៣៩
៥.២ ការកាត់បន្ថយហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង ............................................................ ៤០
៥.៣ ការដាក់ពិន័យ....................................................................................................................៤១
៦. ការគ្រប់គ្រងហិរញ្ញវត្ថុ ........................................................................................................ ៤៥
៦.១ រចនាសម្ព័ន្ធនៃការគ្រប់គ្រងហិរញ្ញវត្ថុ ................................................................................. ៤៥
៦.២ ចរន្តថវិកា........................................................................................................................... ៤៨
៦.៣ គណនេយ្យ និង ការថែរក្សាកកំណត់ត្រាគណនេយ្យ ............................................................ ៥០
៦.៣.១ ប្រាក់រដ្ឋទេយ្យ ................................................................................................................ ៥០
៦.៣.១.១ ការបំពេញឡើងវិញនៃកញ្ចប់ប្រាក់រដ្ឋទេយ្យ.....................................................................៥១
៦.៣.១.២ ការរាប់សាច់ប្រាក់ជាទៀងទាត់ .......................................................................................៥២
៦.៣.១.៣ ការរាប់ក្រដាសប្រាក់ដោយថៃដន្យដែលមិនជូនដំណឹងមុន ................................................៥២
៦.៣.២ ធនាគារ.............................................................................................................................៥២
៦.៣.២.១ គណនីធនាគារ.................................................................................................................៥២
៦.៣.២.២ ហត្ថលេខាដែលមានសិទ្ធ..................................................................................................៥៣
៦.៣.២.៣ អ្នកគ្រប់គ្រងមូលប្បទានប័ត្រ និង សេចក្តីណែនាំសម្រាប់រៀបចំមូលប្បទានប័ត្រ ...៥៣
៦.៣.២.៤ ការផ្ទៀងផ្ទាត់នឹងធនាគារ ............................................................................................... ៥៤
៦.៣.២.៥ ជំហានសម្រាប់រៀបចំ ផ្ទៀងផ្ទាត់នឹងធនាគារ..................................................................... ៥៤
៦.៣.៣ គណនេយ្យសម្រាប់ចំណូល................................................................................................ ៥៥
៦.៣.៤ គណនេយ្យសម្រាប់ការចំណាយ .......................................................................................... ៥៦
៦.៣.៤.១ ការទូទាត់ពីប្រាក់រដ្ឋទេយ្យ ............................................................................................. ៥៨
៦.៣.៤.២ ការទូទាត់តាមធនាគារ...................................................................................................... ៥៩

៦.៣.៥ ការគ្រប់គ្រងបុរេប្រទាន ....................................................................................................៦១

៦.៣.៥.១ សំណើសុំប្រាក់បុរេប្រទាន....................................................................................................៦១

៦.៣.៥.២ ការជំរះថវិកាបុរេប្រទាន ....................................................................................................៦២

៦.៣.៥.៣ ការសម្របសម្រួលថវិកាបុរេប្រទាន.......................................................................................... ៦៤

៦.៣.៦ ការត្រួតពិនិត្យសារពើភ័ណ្ឌ ....................................................................................................... ៦៤

៦.៣.៦.១ ការបញ្ចូលស្តុក........................................................................................................................ ៦៥

៦.៣.៦.២ ការបញ្ចេញពីស្តុក....................................................................................................................៦៦

៦.៣.៦.២ ការរាប់ចំនួន និងការទូទាត់បញ្ជី..............................................................................................៦៦

៦.៤ អចលនទ្រព្យ .............................................................................................................................៦៧

៦.៤.១ ការចុះបញ្ជីអចលនទ្រព្យ.............................................................................................................៦៧

៦.៤.២ ការរាប់ អចលនទ្រព្យ ដាក់ស្លែង ................................................................................................៦៨

៦.៤.៣ ការទុកដាក់ឯកសារ.................................................................................................................៦៨

៦.៥ ការថែទាំកំណត់ត្រាហិរញ្ញវត្ថុ ....................................................................................................៦៨

៦.៦ របាយការណ៍ហិរញ្ញវត្ថុ............................................................................................................. ៦៩

៦.៦.១ របាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ................................................................................................. ៦៩

៦.៦.២ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស .........................................................................................៧០

៦.៦.២.១ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសនៃអង្គភាពប្រតិបត្តិនីមួយៗ ...........................................៧០

៦.៦.២.៣ មន្ទីរសុខាភិបាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួមប្រចាំត្រីមាសនៃមន្ទីរសុខាភិបាល មន្ទីរពេទ្យខេត្ត ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព .............................៧១

៦.៦.៣ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស និងប្រចាំឆ្នាំ........................................................................៧២

៦.៧ សវនកម្ម......................................................................................................................................៧២

៦.៧.១ លក្ខណៈវិនិច្ឆ័យសម្រាប់ទទួលថវិកាផ្សារភ្ជាប់ស្នាដៃការងារ .......................................................៧២

៦.៧.២ សវនកម្មខាងក្រៅ ........................................................................................................ ៧២

៧.លទ្ធកម្ម ........................................................................................................ ៧៣

៧.១ គោលការណ៍ទូទៅ ........................................................................................................ ៧៣

៧.២ និតិវិធីលទ្ធកម្មនៃថវិការសម្រាប់ការផ្តល់សេវា ........................................................................................................ ៧៤

៧.៣ ការកសាងសមត្ថភាពផ្នែកលទ្ធកម្ម ........................................................................................................ ៧៥

៧.៤ ផែនការលទ្ធកម្ម និងតម្រូវការពិនិត្យឡើងវិញ ........................................................................................................ ៧៥

៧.៥ ដែនកំណត់ និងវិធីសាស្រ្ត នៃលទ្ធកម្ម ........................................................................................................ ៧៥

៧.៦ ឯកសារលទ្ធកម្ម ........................................................................................................ ៧៧

៧.៧ ប្រព័ន្ធដោះស្រាយការតវ៉ាអំពីលទ្ធកម្ម ........................................................................................................ ៧៧

៨. ការទិញ ........................................................................................................ ៧៩

៨.១ វិធីសាស្រ្តទិញពីរបែប ........................................................................................................ ៧៩

៨.២ ការទិញធម្មតា ........................................................................................................ ៨០

៨.៣ ការទិញដោយមានការដាក់ប្រមាណតម្លៃពីអ្នកលក់ ........................................................................................................ ៨០

ឧបសម្ព័ន្ធ ........................................................................................................ ៨២

# មាតិកាតារាង

តារាងទី ១ ការបែងចែកកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាលសម្រាប់ឆ្នាំ២០១៦ ........ ១៩
តារាងទី ២ ស្ថាប័ន និងកិច្ចការទាក់ទងទៅនឹងការវាយតម្លៃមុនផ្តល់ថវិកា និងការវាយតម្លៃផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកា មកពីខាងក្រៅ ........ ២៩
តារាងទី ៣ តារាងនៃការចំណាយដែលមានសិទ្ធប្រើប្រាស់មូលនិធិសម្រាប់ផ្តល់សេវា ........ ៣៦
តារាងទី ៤ ការពិន័យក្នុងករណីដែលលទ្ធផលខុសគ្នា លើសពី ១០% មិនអាចពន្យល់បានពីការផ្ទៀងផ្ទាត់ក្រោយការវាយតម្លៃ ........ ៤៣
តារាងទី ៥ សង្ខេបអំពីតួនាទី ភារៈកិច្ច ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ថ្នាក់ មន្ទីរសុខាភិបាលខេត្ត មន្ទីរពេទ្យខេត្ត ស្រុកប្រតិបត្តិ និង មន្ទីរពេទ្យបង្អែក ........ ៤៦
តារាងទី ៦ សង្ខេបអំពីការទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់មណ្ឌលសុខភាព ........ ៤៧
តារាងទី ៧ ការបំពេញឡើងវិញនៃប្រាក់រដ្ឋទេយ្យ ........ ៥១
តារាងទី ៨ ហត្ថលេខាមានសិទ្ធិជាផ្លូវការ ........ ៥៣
តារាងទី ៩ រៀបចំការផ្ទៀងផ្ទាត់នឹងធនាគារ ........ ៥៤
តារាងទី ១0 ប័ណ្ណចំណូលជាផ្លូវការ ........ ៥៥
តារាងទី ១១ ប្រភេទឯកសារសម្រាប់ការទូទាត់ ........ ៥៧
តារាងទី ១២ ដែនកំណត់នៃលទ្ធកម្ម ........ ៧៦

## មាតិការូបភាព


រូបភាពទី ១ ការរៀបចំស្ថាប័ននៃ មូលនិធិសម្រាប់ផ្តល់សេវា

រូបភាពទី ២ រចនាសម្ព័ន្ធគ្រប់គ្រង ហិរញ្ញវត្ថុ សម្រាប់ មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មន្ទីរពេទ្យខេត្ត និង មន្ទីរពេទ្យបង្អែក

រូបភាពទី ៣ រចនាសម្ព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់មណ្ឌលសុខភាព

រូបភាពទី ៤ គំនូសតាងចរន្តថវិកា នៃប្រភពថវិកាទាំងពីរ

# អារម្ភកថា

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងធ្វើការកែលម្អលើកកម្ពស់ការផ្តល់សេវានិង គុណភាពសេវាសុខាភិបាល។ ការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ ២០១៦-២០២០ គឺជាជំហានចម្បងក្នុងការសម្រេចបាននូវគោលដៅនេះ។ ផែនការយុទ្ធសាស្ត្រសុខាភិបាល បានបង្ហាញនូវការប្តេជ្ញារបស់ មន្ត្រីនៃរាជរដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់នៃប្រព័ន្ធសុខាភិបាល ដៃគូអភិវឌ្ឍន៍ និងសហគមន៍ ក្នុងការឈានទៅសម្រេចបាន នូវគោលដៅនៃ ផែនការយុទ្ធសាស្ត្រសុខាភិបាលលើកទី៣ នៅឆ្នាំ២០២០។

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត នូវគោលនយោបាយនៃការផ្តល់សេវាសាធារណៈ សម្រាប់ជា មូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍គ្រប់វិស័យ។ គោលនយោបាយនេះជាត្រីវិស័យសម្រាប់ក្រសួងនានាក្នុងការបន្តកែលម្អសេវាសាធារណៈ។ ការអភិវឌ្ឍន៍គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល គឺជាឧបករណ៍មួយក្នុងការកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈបានឆាប់រហ័ស ហើយជាកត្តាគន្លឹះមួយក្នុងវឌ្ឍនភាពនេះ។

គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល រួមមានសមាសធាតុសំខាន់ៗចំនួនបីគឺ (១) ពង្រឹងការផ្តល់សេវាតាមរយៈ មូលនិធិសម្រាប់ផ្តល់សេវា (២) កែលម្អយន្តការគាំពារហិរញ្ញវត្ថុ និងសមធម៌ តាមរយៈមូលនិធិសមធម៌ (៣) ធានានិរន្តរភាពនិងការទទួលខុសត្រូវនៃប្រព័ន្ធសុខាភិបាល។ ក្នុងខណៈដែលមូលនិធិសមធម៌ជួយបង្កើនការប្រើប្រាស់សេវាសុខាភិបាលដោយប្រជាពលរដ្ឋក្រីក្រ ការរៀបចំនូវមូលនិធិសម្រាប់ផ្តល់សេវាសុខាភិបាលនេះគឺផ្តោតសំខាន់ទៅលើការកែលម្អគុណភាពសេវាសុខាភិបាល។

បន្ថែមលើការកែលម្អគុណភាពដែលជាចំណុចផ្តោតសំខាន់នេះ ការធ្វើវិមជ្ឈការអំណាចទៅដល់ថ្នាក់ក្រោម ក៏ជាគន្លឹះសំខាន់ក្នុងការរួមចំណែកសម្រេចបានជោគជ័យ នៃយន្តការហិរញ្ញប្បទានរយៈពេលវែង តាមរយៈនិរន្តរភាពនៃការគៀងគរធនធាន ។ មូលនិធិសម្រាប់ផ្តល់សេវា នឹងដាក់ជូនដល់មូលដ្ឋានសុខាភិបាលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមស្តង់ដារអប្បបរមានៃគុណភាព និងការគ្រប់គ្រង។ មូលនិធិនេះនឹងប្រើប្រាស់ជាជំនួយផ្ទាល់ដល់ មូលដ្ឋានសុខាភិបាលសាធារណៈ ដើម្បីបង្កភាពងាយស្រួល និងលើកទឹកចិត្តឲ្យគេផ្តល់សេវាសុខាភិបាល ប្រកបដោយគុណភាព ដល់

ប្រជាពលរដ្ឋ។ ការកើនឡើងជាបណ្តើរៗនៃថវិការបស់រាជរដ្ឋាភិបាល ក្នុងមូលនិធិសម្រាប់ផ្តល់សេវាជានាទូវនិរន្តរភាពនៃថវិកា ដោយកាត់បន្ថយជាបណ្តើរៗ នូវភាពពឹងផ្អែកលើជំនួយពីខាងក្រៅ។

គោលបំណងនៃសេចក្តីណែនាំសម្រាប់ប្រតិបត្តិការ មូលនិធិសម្រាប់ផ្តល់សេវា នេះផ្តល់នូវការណែនាំសម្រាប់អនុវត្តនៃសមាសធាតុទីមួយរបស់ គម្រោងលើកកម្ពស់គុណភាពនិងសមធម៌សុខាភិបាលជាពិសេស ការណែនាំពីរបៀបប្រើប្រាស់ មូលនិធិសម្រាប់ផ្តល់សេវាសុខាភិបាល ដែលជាយន្តការហិរញ្ញវត្ថុ ដើម្បីកែលម្អគុណភាពសេវានៅគ្រប់លំដាប់ថ្នាក់នៃប្រព័ន្ធសុខាភិបាលសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា។ សេចក្តីណែនាំនេះនឹងបរិយាយលម្អិត សម្រាប់អនុវត្ត យន្តការជាតិបង្កើនគុណភាព ក៏ដូចជាការវាស់វែងស្នាដៃការងារ លក្ខណៈសម្បត្តិសម្រាប់ការផ្តល់ មូលនិធិសម្រាប់ផ្តល់សេវាសុខាភិបាល ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ ចំណាយដែលអាចប្រើប្រាស់ មូលនិធិសម្រាប់ផ្តល់សេវាសុខាភិបាលបាន ការគ្រប់គ្រងហិរញ្ញវត្ថុ និង និតិវិធីលទ្ធកម្ម ដែលតម្រូវឲ្យអនុលោមតាម។

សេចក្តីណែនាំនេះបរិយាយអំពី តួនាទី និងទំនាក់ទំនង និងការប្រើប្រាស់ ដែនកំណត់នៃមូលនិធិសម្រាប់ផ្តល់សេវា។ សេចក្តីណែនាំនេះក៏បានបង្ហាញនូវបែបបទ ប្រព័ន្ធ និងផ្តល់នូវការណែនាំសម្រាប់បែបបទនីមួយៗ ដោយមានឯកសារគាំទ្រពីឧបសម្ព័ន្ធនានា។ នេះគឺជាឯកសារសម្រាប់ប្រតិបត្តិការ ដែលអាចធ្វើការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ទៅតាមការប្រែប្រួលនៃទម្រង់ប្រតិបត្តិការជាក់ស្តែង។

ខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា សេចក្តីណែនាំប្រតិបត្តិនេះនឹងមានសារៈប្រយោជន៍ដល់ប្រព័ន្ធសុខាភិបាលគ្រប់លំដាប់ថ្នាក់ ក្នុងការឈានទៅសម្រេចបានការកែលម្អគុណភាពសេវាសុខាភិបាលសាធារណៈ។

**សាស្ត្រាចារ្យ អេង ហួត**
**រដ្ឋលេខាធិការ និងជានាយកគម្រោង**
**លើកកម្ពស់គុណភាពនិងសមធម៌សុខាភិបាល**

# ១. បរិយាយអំពី មូលនិធិសម្រាប់ផ្តល់សេវា

*មូលនិធិសម្រាប់ផ្តល់សេវា នេះមានសមាសធាតុមិនប្រែប្រួលមួយ ដែលមានឈ្មោះថា កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល និងសមាសធាតុដែលប្រែប្រួលទៅតាមស្នាដៃការងារ ដែលហៅថាកញ្ចប់ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ។ កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាលនេះ ត្រូវបានផ្តល់ថវិកាទាំងស្រុងដោយរាជរដ្ឋាភិបាលកម្ពុជា ចំណែកឯថវិកាផ្សារភ្ជាប់ស្នាដៃការងារគឺត្រូវបានផ្តល់ថវិការួមគ្នា ដោយរាជរដ្ឋាភិបាលកម្ពុជា ជំនួយអភិវឌ្ឍន៍អន្តរជាតិ* (IDA) និង មូលនិធិត្រាស់ហ្វាន់ពហុភាគី (MDTF) ។

## ១.១ បរិយាយអំពីកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល

*កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាលជាថវិការបស់រដ្ឋាភិបាលដែលត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការសម្រាប់វិស័យសុខាភិបាលជាលើកដំបូងនៅក្នុងថវិកាឆ្នាំ ២០១៦ ។ ថវិកាទាំងនេះត្រូវបានបែងចែកទៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកទូទាំងប្រទេសក្នុងបរិមាណថេរសម្រាប់ការចំណាយប្រតិបត្តិការបន្ថែមទៅលើថវិកាប្រតិបត្តិ ដែលបានកំណត់នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ពួកគេ* (AOPs) *។ ថវិកាទាំងនេះ មានចំនួន ៦,៨ លានដុល្លាអាមេរិកសម្រាប់ឆ្នាំ២០១៦ ។*

*តារាងទី១ សង្ខេបចំនួនកញ្ចប់ថវិកាសម្រាប់ប្រតិបត្តការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល ដែលបានបែងចែកទៅតាមប្រភេទ នៃមូលដ្ឋានសុខាភិបាលនីមួយៗ សម្រាប់ឆ្នាំ២០១៦៖ ១២លានរៀល (ឬប្រហាក់ប្រហែល៣.០០០ដុល្លាអាមេរិក) សម្រាប់មណ្ឌលសុខភាពនីមួយៗ និង១០០លានរៀល ១៥០លានរៀល និង២០០លានរៀល (ឬប្រហាក់ប្រហែល ២៥,០០០ដុល្លាអាមេរិក ៣៧,៥០០ដុល្លាអាមេរិក និង៥០,០០០ដុល្លាអាមេរិក) សម្រាប់មន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣។ ប្រកាសអន្តរក្រសួងលេខ៣០២សហវ/ប្រក ត្រូវបានបង្កើតឡើងនិងចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាលនៅថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៦ ក្នុងគោលបំណងដើម្បីពង្រឹង និងបង្កើនគណនេយ្យភាព ព្រមទាំងតម្លាភាពនៃការគ្រប់គ្រង និងការចំណាយនៃកញ្ចប់ថវិកាសម្រាប់ប្រតិបត្តការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាលនេះ ។*

តារាងទី ១៖ ការបែងចែកកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាលសម្រាប់ឆ្នាំ២០១៦

| មូលដ្ឋានសុខាភិបាល | ការបែងចែកថវិកា/មូលដ្ឋានសុខាភិបាល/ឆ្នាំ២០១៦ (គិតជាប្រាក់រៀល) | ការបែងចែកថវិកា/មូលដ្ឋានសុខាភិបាល/ឆ្នាំ២០១៦ (គិតជាតម្លៃប្រហាក់ប្រហែលជាដុល្លាអាមេរិក) |
|---|---|---|
| មណ្ឌលសុខភាព | ១២,០០០,០០០ | ៣,០០០ |
| មន្ទីរពេទ្យបង្អែកកម្រិត១ | ១០០,០០០,០០០ | ២៥,០០០ |
| មន្ទីរពេទ្យបង្អែកកម្រិត២ | ១៥០,០០០,០០០ | ៣៧,៥០០ |
| មន្ទីរពេទ្យបង្អែកកម្រិត៣ | ២០០,០០០,០០០ | ៥០,០០០ |

អត្រាប្តូរប្រាក់ ១ដុល្លាអាមេរិក = ៤,០០០ រៀល

តារាងរាយមុខចំណាយដែលអាចចាយបាន មានបរិយាយនៅក្នុងផ្នែកទី៥ នៃសេចក្តីណែនាំនេះ។

នៅថ្ងៃអនាគត ការបែងចែកកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល នឹងធ្វើការកែសម្រួលដោយផ្អែកលើលក្ខណៈប្រជាសាស្ត្រ ស្ថានភាពភូមិសាស្ត្រ និងតម្រូវការ នៃការកែលម្អគុណភាពសេវា និងការពង្រីកសេវាគ្របដណ្តប់សុខាភិបាល។

## ១.២ បរិយាយអំពី កញ្ចប់ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ

ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ គឺជាថវិកាដែលនឹងផ្តល់ជូនមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាលខេត្ត ដោយផ្អែកលើពិន្ទុនៃលទ្ធផលវាយតម្លៃការងារ

របស់ពួកគេតាមរយៈ សំណុំឧបករណ៍តាមដានកែលម្អគុណភាពសេវាសុខាភិបាល ដែលជាប្រព័ន្ធព័ត៌មានបច្ចេកវិទ្យាទំនើបថ្មី ។ ផ្នែកទី៤ នឹងបរិយាយថាតើលទ្ធផលស្នាដៃការងារ នេះ នឹងត្រូវបានវាយតម្លៃ និង ផ្ទៀងផ្ទាត់ យ៉ាងដូចម្តេច ។

ថវិកាផ្សារភ្ជាប់នឹងស្នាដៃកាងារ នឹងត្រូវធ្វើការកំណត់យោងតាម គោលបំណង និងលទ្ធផលដែលបានពីការកែលម្អគុណភាពនេះ ។ ថវិកាផ្តល់ទៅមណ្ឌលសុខភាពនឹងផ្អែកទៅលើសំណុំសកម្មភាពអប្បបរមា (MPA) របស់ពួកគេ ។ គុណភាពសេវាខ្ពស់ ជាកត្តានៃការបង្កើនទំហំថវិកាដែលផ្តល់ជូន ដោយហេតុថាគុណភាពខ្ពស់ នឹងមានឥទ្ធិពលទៅលើប្រសិទ្ធភាពសេវា និងនាំឲ្យមានតម្រូវការខ្ពស់លើសេវានេះ ។ ថវិកាដែលផ្តល់ជូនមន្ទីរពេទ្យបង្អែកនឹងផ្អែកទៅលើគុណភាពនៃសំណុំសកម្មភាពបង្គ្រប់ និងកម្រិតនៃការចូលរួម កសាងសមត្ថភាព និងការលើកកម្ពស់សមធម៌របស់ពួកគេ ។ ថវិកាដែលផ្តល់ជូនស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាល ផ្អែកលើកម្រិតនៃលទ្ធផលការងារ ទាក់ទងនឹងអភិបាលកិច្ច ការបង្ហាត់បង្ហាញ និងការកសាងសមត្ថភាព ។ ស្វ័យភាពនឹងត្រូវផ្តល់ជូនមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងការិយាល័យស្រុកប្រតិបត្តិ/មន្ទីរសុខាភិបាលខេត្ត សម្រាប់ការប្រើប្រាស់កញ្ចប់ថវិកា ទៅតាម តារាងពយមុខសម្រាប់ការចំណាយដែលអាចចាយបាន ។

សមាសជាតុ នៃកញ្ចប់ថវិកា ផ្អែកលើលទ្ធផលការងារនេះ គឺ មានចំនួន ៤០លាន ដុល្លាអាមេរិក នៃគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល ក្នុងរយៈកាលពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ ដែលមានថវិកាបដិភាគស្មើគ្នាដោយរាជរដ្ឋាភិបាលកម្ពុជា និង ជំនួយអភិវឌ្ឍន៍អន្តរជាតិ/មូលនិធិត្រាស់ហ្វាន់ពហុភាគី ។ កញ្ចប់ថវិកាអតិបរមាប្រចាំឆ្នាំ សម្រាប់ មូលដ្ឋានសុខាភិបាលនីមួយៗ នេះ នឹងត្រូវកំណត់ ដោយផ្អែកលើមេរៀនជាបទពិសោធន៍ដែលបានមកពីគម្រោងសាកល្បង ។

## ១.៣ មូលនិធិសម្រាប់ផ្តល់សេវា និង យន្តការជាតិនៃការបង្កើនគុណភាព

គុណភាពនៃការថែទាំគឺជាកត្តាកំណត់លទ្ធផលសុខភាពដ៏សំខាន់ ។ កម្រិតទាបនៃការថែទាំនាំឲ្យផលប្រយោជន៍ដល់សុខភាពមានកម្រិតទាបជាងកម្រិតដែលនឹងសម្រេចបានដោយការវិនិយោគបច្ចុប្បន្នលើវិស័យសុខាភិបាល។ ការសិក្សាទូទាំងប្រទេសក្នុងឆ្នាំ២០១៥ ដោយប្រើប្រាស់ឧបករណ៍វាយតម្លៃគុណភាពសេវាសុខាភិបាល កម្រិតទី២ បានរកឃើញថា គុណភាពនៃការថែទាំដែលបានផ្តល់ជូនដោយមូលដ្ឋានសុខាភិបាលសាធារណៈចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើង

*បន្ថែមទៀត។ ដូច្នេះការវិនិយោគលើការកែលម្អគុណភាព គឺជាអាទិភាពសំខាន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍។*

*មូលនិធិសម្រាប់ផ្តល់សេវា នឹងអនុញ្ញាតឲ្យមូលដ្ឋានសុខាភិបាលសាធារណៈ ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការថែទាំ។ កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល នេះផ្តល់មធ្យោបាយងាយស្រួលដល់មូលដ្ឋានសុខាភិបាលនូវថវិកាបន្ថែម និងអាចបត់បែនបាន សម្រាប់ការប្រជុំបន្ទាន់ និងចំណាយប្រតិបត្តិការចាំបាច់ដើម្បីកែលម្អលក្ខខណ្ឌអប្បបរមា សម្រាប់ការផ្តល់សេវាសុខភាពដែលមានគុណភាព ។ ជាមួយគ្នានេះដែរ ថវិកាផ្សារភ្ជាប់ស្នាដៃការងារ ដែលផ្តោតជាចម្បងលើគុណភាពនៃការថែទាំនឹងជម្រុញលើកទឹកចិត្តដល់អ្នកផ្តល់សេវាសុខភាពសាធារណៈ និងមូលដ្ឋានសុខាភិបាល ដើម្បីកែលម្អគុណភាពនៃការថែទាំ តាមរយៈការវាយតម្លៃជាទៀងទាត់ និងមានប្រសិទ្ធិភាព ព្រមទាំងការបង្វឹកការងារដោយការិយាល័យស្រុកប្រតិបត្តិ និង មន្ទីរសុខាភិបាលខេត្ត ។*

*ឧបករណ៍វាយតម្លៃគុណភាពសេវាសុខាភិបាលពិសេស ត្រូវបានបង្កើតឡើង ហើយនិងដាក់ឲ្យអនុវត្តជាទៀងទាត់នៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក។ ឧបករណ៍ទាំងនេះហៅថា សំណុំឧបករណ៍តាមដានការកែលម្អគុណភាពសេវាសុខាភិបាល ថ្នាក់ជាតិ (NQEMT) ដែលមានចែងក្នុងឯកសារនេះ ត្រូវប្រើប្រាស់ចាប់ពីនេះតទៅ ។ ការិយាល័យស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាលខេត្តនឹងស្ថិតក្រោមក្របខ័ណ្ឌស្នាដៃការងារដើម្បីពង្រឹងមុខងាររបស់ខ្លួន ។ ការទូទាត់ប្រាក់នឹងត្រូវប្រើប្រាស់យន្តការវាយតម្លៃស្នាដៃការងារ ។ ការផ្ទៀងផ្ទាត់នឹងត្រូវអនុវត្តដោយប្រើយន្តការភាគីទីបី ដូចគ្នានឹងយន្តការមួយដែលបានប្រើប្រាស់នាពេលបច្ចុប្បន្នសម្រាប់មូលនិធិសមធម៌ រហូតដល់ ទីភ្នាក់ងារសម្រាប់ផ្ទៀងផ្ទាត់ការទូទាត់ (PCA) ត្រូវបានបង្កើតឡើង ។ ការប្រសើរឡើងនៃគុណភាពថែទាំនៅតាមមណ្ឌលសុខភាព និង មន្ទីរពេទ្យបង្អែកសាធារណៈ ត្រូវបានរំពឹងទុកថា នឹងកើតឡើងយ៉ាងឆាប់រហ័សនៅទូទាំងប្រទេស។*

## ១.៤ លក្ខណៈវិនិច្ឆ័យដើម្បីទទួលបាន ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ

*ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ នឹងត្រូវធ្វើការបែងចែកដោយផ្អែកលើពិន្ទុនៃការវាយតម្លៃ។ ពិន្ទុនេះត្រូវបានវាស់នៅលើមាត្រដ្ឋានពី ០% ទៅ ១០០% ។ ឧទាហរណ៍ប្រសិនបើ មូលដ្ឋានសុខាភិបាល (មន្ទីរសុខាភិបាល ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព) បានទទួលពិន្ទុ*

*៨០% ពួកគេនឹងទទួលបាន ៨០% នៃថវិកាផ្សារភ្ជាប់នឹងស្នាដៃការងាររបស់ខ្លួនពីមូលនិធិសម្រាប់ផ្តល់សេវា ។*

## ២. ការរៀបចំស្ថាប័ន (រចនាសម្ព័ន្ធគ្រប់គ្រង)

*ការពង្រឹងលទ្ធផលដែលមានគុណភាពគឺជាគោលបំណងចម្បងនៃការរៀបចំស្ថាប័នក្នុងយន្តការតាមដានការបង្កើនគុណភាពថ្នាក់ជាតិ* (NQEMP) *។ ស្ថាប័នដែលបានរៀបចំនេះប្រើប្រាស់ប្រព័ន្ធ និង នីតិវិធី របស់ជាតិ ដែលមានបង្ហាញនៅក្នុងរូបភាពទី១ ខាងក្រោម ។*

*រូបភាពទី ១៖ ការរៀបចំស្ថាប័ននៃ មូលនិធិសម្រាប់ផ្តល់សេវា*



## ២.១ តួនាទី និងការទទួលខុសត្រូវមានដូចតទៅ:

- *នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល:* (ជាពិសេសការិយាល័យធានាគុណភាពសេវាសុខាភិបាលដែលគាំទ្រដោយគណៈកម្មការបច្ចេកទេស) ទទួលបន្ទុកកម្មវិធីគ្រប់គ្រងការកែលម្អគុណភាពសេវា ។ តួនាទីនិងការទទួលខុសត្រូវមានដូចតទៅៈ

  (១) រៀបចំ និងធ្វើបច្ចុប្បន្នភាព សេចក្តីណែនាំប្រតិបត្តិ មូលនិធិសម្រាប់ផ្តល់សេវា និងឧបករណ៍តាមដានការកែលម្អគុណភាពសេវាថ្នាក់ជាតិ (២) កំណត់ស្តង់ដាគុណភាព (៣) ការរៀបចំវគ្គបណ្តុះបណ្តាលអ្នកវាយតម្លៃ សម្រាប់ស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាល និងអ្នកវាយតម្លៃពីខាងក្រៅ សម្រាប់ការផ្ទៀងផ្ទាត់ (៤) ធ្វើការផ្តល់វិញ្ញាបនប័ត្រដល់អ្នកវាយតម្លៃមន្ទីរសុខាភិបាល ស្រុកប្រតិបត្តិ និងអ្នកវាយតម្លៃពីខាងក្រៅ។ គ្រប់គ្រងកម្មវិធីបណ្តាញគេហទំព័រដែលបានអនុញ្ញាតឲ្យប្រើប្រាស់ (៥) អភិបាលគាំទ្រនៅតាមមូលដ្ឋានសុខាភិបាល / ត្រួតពិនិត្យតាមដាន (៦) វិភាគទិន្នន័យស្នាដៃការងារ និង ផ្តល់នូវព័ត៌មានត្រឡប់ទៅនាយកគ្រប់គ្រងគម្រោង អ្នកគ្រប់គ្រងជាន់ខ្ពស់នៃក្រសួងសុខាភិបាល អង្គការដៃគូនៃគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល និងនាយកដ្ឋានរដ្ឋបាលក្រសួងសុខាភិបាល (៧) ធ្វើការវាយតម្លៃគុណភាពសេវាសុខាភិបាលប្រចាំឆមាសទូទាំងប្រទេស និង (៨) អនុវត្តមុខងារជាលេខាធិការដល់ក្រុមការងារលើកកម្ពស់គុណភាពសេវា (៩) ចូលរួម និងផ្តល់នូវធាតុចូលដែលចាំបាច់ដើម្បីការអភិវឌ្ឍន៍ ភ្នាក់ងារផ្ទៀងផ្ទាត់ការទូទាត់ ។

- *ក្រុមការងារលើកកម្ពស់គុណភាពសេវា:* ដឹកនាំដោយនាយកគម្រោងគ្រប់គ្រងសេវាសុខាភិបាល គាំទ្រដោយគណៈកម្មការបច្ចេកទេស/ការិយាល័យធានាគុណភាព និងដៃគូអភិវឌ្ឍន៍។ ធ្វើការរៀបចំវេទិកាដែលបង្ហាញលទ្ធផលពីត្រីមាសកន្លងមក ពិភាក្សា និងធ្វើឱ្យមានសុពលភាពមុនពេលដាក់ស្នើទៅកាន់នាយកគម្រោងសម្រាប់ការអនុម័ត។ បន្ទាប់ពីការអនុម័ត បញ្ជាទូទាត់អាចត្រូវដំណើរការដោយនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុនៃក្រសួងសុខាភិបាល។ លទ្ធផលបានមកពីការវាយតម្លៃផ្ទៀងផ្ទាត់ពីខាងក្រៅ ត្រូវបានបង្ហាញក្នុងវេទិកានេះផងដែរដើម្បីពិភាក្សាដោយក្រុមការងារលើកកម្ពស់គុណភាពសេវា និងការសម្រេចចិត្តចុងក្រោយដោយនាយកគ្រប់គ្រងគម្រោង។

- ***នាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ:*** *នាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ* (DBF) *នឹងទូទាត់កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាលដល់មូលដ្ឋានសុខាភិបាលប្រចាំខែ ឬត្រីមាស និងថវិកាផ្សារភ្ជាប់ស្នាដៃការងារដោយយោងតាមលទ្ធផលនៃការវាយតម្លៃស្នាដៃការងារប្រចាំត្រីមាស នៃការវាយតម្លៃស្នាដៃការងារត្រីមាសមុន ដែលបានឯកភាពដោយនាយកគម្រោងជាមួយនឹងការវិនិច្ឆ័យដោយផ្អែកលើលទ្ធផលក្រោយការផ្ទៀងផ្ទាត់ពីខាងក្រៅជាចាំបាច់ ។*
- ***វិទ្យាស្ថានជាតិ សុខភាពសាធារណៈ:*** (NIPH): *វិទ្យាស្ថាននឹងចូលរួមជាមួយនឹងដំណើរការនៃការអភិវឌ្ឍន៍ឧបករណ៍តាមដានការបង្កើនគុណភាពថ្នាក់ជាតិ និងការផ្តល់ប្រឹក្សាបច្ចេកទេសដល់ក្រុមយន្តការជាតិតាមដានការបង្កើនគុណភាព* (NQEMP) ។
- ***ភ្នាក់ងារភាគីទីបី:*** *គឺជាភ្នាក់ងារឯករាជ្យដែលចាត់តាំងឡើងដោយ គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល ដើម្បីផ្ទៀងផ្ទាត់លទ្ធផលដែលទទួលបានតាមរយៈការវាយតម្លៃមុនផ្តល់ថវិកា ពីអ្នកវាយតម្លៃខាងក្រៅ ។ សកម្មភាពនេះត្រូវបានគេហៅថា "ការផ្ទៀងផ្ទាត់តាមក្រោយពីអ្នកវាយតម្លៃខាងក្រៅ" ។ ការផ្ទៀងផ្ទាត់តាមក្រោយពីអ្នកវាយតម្លៃខាងក្រៅប្រើប្រាស់ល្បាយនៃសំណាកគំរូដោយចៃដន្យ និងសំណាកគំរូផ្អែកលើហានិភ័យដើម្បីវាយតម្លៃគុណភាព និងភាពត្រឹមត្រូវនៃការវាយតម្លៃមុនដំបូងពីអ្នកវាយតម្លៃខាងក្រៅ ។*
- ***មន្ទីរសុខាភិបាលខេត្ត:*** *មានមុខងារ និងការទទួលខុសត្រូវជាក់លាក់សម្រាប់ស្រុកប្រតិបត្តិ និងមន្ទីរពេទ្យ ។ ការទទួលខុសត្រូវជាក់លាក់ទាំងនេះ សំខាន់គឺទាក់ទងទៅនឹងគុណភាពសេវាសុខាភិបាលត្រូវបានកំណត់នៅក្នុងក្របខ័ណ្ឌនៃស្នាដៃការងារមួយ ។ សកម្មភាពសំខាន់ៗនៃការិយាល័យមន្ទីរសុខាភិបាលខេត្ត ដែលជាប់ពាក់ព័ន្ធទៅនឹង យន្តការជាតិតាមដានការបង្កើនគុណភាព គឺៈ (១) ការចូលរួមក្នុងការបណ្តុះបណ្តាល និងដំណើរការនៃការផ្ទៀងផ្ទាត់លើអ្នកវាយតម្លៃថ្នាក់ខេត្ត (២) ការវាយតម្លៃលើគុណភាពសេវានៃមន្ទីរពេទ្យបង្អែក (កម្រិត១ កម្រិត២ កម្រិត៣) (៣) ធ្វើការបង្វឹកការងារចំនួនពីរជុំដល់មន្ទីរពេទ្យបង្អែក ទៅតាមជុំដែលអនុវត្តការវាយតម្លៃនីមួយៗ (៤) ការវាយតម្លៃលើស្នាដៃការងាររបស់ស្រុកប្រតិបត្តិ (៥) ជួយដល់មន្ទីរពេទ្យបង្អែកនៅក្នុងការកំណត់គោលដៅចំណុចដើម្បីកែលម្អគុណភាពសេវាប្រចាំត្រីមាស និងប្រចាំឆ្នាំ (៦) ការវាយតម្លៃគុណភាពស្នាដៃការងាររបស់មន្ទីរសុខាភិបាលនៅខេត្តផ្សេងគ្នា (៧) ការត្រួតពិនិត្យតាមដាននិន្នាការនៃ*

*ការកែលម្អគុណភាពសេវានៃមូលដ្ឋានសុខាភិបាលដែលស្ថិតនៅក្នុងតំបន់គ្របដណ្តប់ និង (៨) អនុវត្តការកិច្ចផ្សេងៗទៀតដែលបានបរិយាយនៅក្នុងបញ្ជីក្របខ័ណ្ឌស្នាដៃការងាររបស់មន្ទីរសុខាភិបាលខេត្ត ។*

- ***ការិយាល័យស្រុកប្រតិបត្តិ:*** *មានមុខងារ និងការទទួលខុសត្រូវជាក់លាក់នៅក្នុងប្រព័ន្ធ សុខាភិបាលស្រុកប្រតិបត្តិ ។ ការទទួលខុសត្រូវជាក់លាក់ទាំងនេះ សំខាន់គឺទាក់ទងទៅនឹងគុណភាពសេវាសុខាភិបាលត្រូវបានកំណត់នៅក្នុងក្របខ័ណ្ឌនៃស្នាដៃការងារមួយ ។ សកម្មភាពសំខាន់ៗនៃស្រុកប្រតិបត្តិដែលជាប់ពាក់ព័ន្ធទៅនឹងយន្តការជាតិតាមដានការបង្កើនគុណភាព គឺ៖ (១) ការចូលរួមក្នុងការបណ្តុះបណ្តាល និងដំណើរការនៃការផ្ទៀងផ្ទាត់លើអ្នកវាយតម្លៃស្រុកប្រតិបត្តិ (២) ការវាយតម្លៃលើគុណភាពសេវានៃមណ្ឌលសុខភាព (៣) ធ្វើការបន្ទឹកការងារចំនួនពីរជុំដល់មណ្ឌលសុខភាពទៅតាមជុំដែលអនុវត្តការវាយតម្លៃនីមួយៗ (៤) ជួយដល់មណ្ឌលសុខភាពនៅក្នុងការកំណត់គោលដៅចំណុចដើម្បីកែលម្អគុណភាពសេវាប្រចាំត្រីមាស និងប្រចាំឆ្នាំ (៥) ការត្រួតពិនិត្យតាមដាននិន្នាការនៃការកែលម្អគុណភាពសេវានៃមណ្ឌលសុខភាពនិងមន្ទីរពេទ្យដែលស្ថិតនៅក្នុងតំបន់គ្របដណ្តប់ និង (៦) អនុវត្តការកិច្ចផ្សេងៗទៀតដែលបានបរិយាយនៅក្នុងបញ្ជីក្របខ័ណ្ឌស្នាដៃការងាររបស់ស្រុកប្រតិបត្តិ។*
- ***អ្នកផ្តល់សេវាសុខាភិបាល:*** *គឺជាមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក (កម្រិត១ កម្រិត២ កម្រិត៣) ដែលផ្តល់សេវាសំណុំសកម្មភាពអប្បបរមា និងសំណុំសកម្មភាពបង្គ្រប់ដោយឡែកផ្សេងៗពីគ្នា។ មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកនីមួយៗនឹងមានកញ្ចប់មូលនិធិសម្រាប់ផ្តល់សេវា ប្រចាំឆ្នាំជាក់លាក់មួយ (កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល និងថវិកាផ្សារភ្ជាប់ស្នាដៃការងារ) ដែលនឹងត្រូវបែងចែកតាមដំណាក់កាលប្រចាំត្រីមាស ។ ភារកិច្ចសំខាន់ៗនៃអ្នកផ្តល់សេវាគឺ: (១) ជួយសម្របសម្រួលការវាយតម្លៃដោយអ្នកវាយតម្លៃផ្ទៀងផ្ទាត់ពីការិយាល័យមន្ទីរសុខាភិបាលខេត្ត/ការិយាល័យស្រុកប្រតិបត្តិ និងអ្នកផ្ទៀងផ្ទាត់មកពីភ្នាក់ងារផ្ទៀងផ្ទាត់ការទូទាត់ (PCA) (២) ការដោះស្រាយភាពទន់ខ្សោយនិងបញ្ហាដែលបានកំណត់បន្ទាប់ពីការវាយតម្លៃពីលើកមុននីមួយៗ (៣) ចូលរួមនៅក្នុងដំណើរការបន្ទឹកដែលធ្វើឡើងដោយអ្នកវាយតម្លៃផ្ទៀងផ្ទាត់ពីការិយាល័យមន្ទីរសុខាភិបាលខេត្ត/ការិយាល័យស្រុកប្រតិបត្តិ (៤) រកវិធីសាស្ត្រដើម្បីឈានទៅដល់គោលដៅប្រចាំត្រីមាស និងប្រចាំឆ្នាំដែលបានកំណត់*

នៅក្នុងផែនការស្នាដៃការងារប្រចាំឆ្នាំ ។ ស្នាដៃការងាររបស់មូលដ្ឋានសុខាភិបាលនឹងត្រូវធ្វើការវាយតម្លៃប្រចាំត្រីមាសដោយអ្នកវាយតម្លៃផ្ទៀងផ្ទាត់មកពី ការិយាល័យស្រុកប្រតិបត្តិ (សម្រាប់មណ្ឌលសុខភាព) និងមកពី ការិយាល័យមន្ទីរសុខាភិបាលខេត្ត (សម្រាប់មន្ទីរពេទ្យបង្អែក) ។

- ***អ្នកទទួលផល:*** *អ្នកទទួលផល គឺជាអតិថិជនដែលប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលសាធារណៈ។ អ្នកទទួលផលនឹងត្រូវផ្តល់បទសម្ភាសន៍តាមរយៈការជ្រើសរើសសំណាកគំរូដោយចៃដន្យជាប្រព័ន្ធ។*

## ៣. ការផ្ទៀងផ្ទាត់គុណភាពស្នាដៃការងារ

ស្នាដៃការងារ លើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ទុកជាមុន នឹងត្រូវវាស់វែង តាមរយៈឧបករណ៍សាមញ្ញមួយដែលគ្រប់គ្រងដោយការិយាល័យធានាគុណភាព(QAO)នៃក្រសួងសុខាភិបាល ហើយដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ។ ឧបករណ៍ទាំងនេះមាន (១) តារាងដាក់ពិន្ទុវាយតម្លៃមួយ (BSC) សម្រាប់មណ្ឌលសុខភាព (២) តារាងដាក់ពិន្ទុវាយតម្លៃមួយសម្រាប់មន្ទីរពេទ្យ (ដែលមានបីប្រភេទគឺ សម្រាប់មន្ទីរពេទ្យបង្អែក កម្រិត១ កម្រិត២ និង កម្រិត៣) (៣) ក្របខ័ណ្ឌស្នាដៃការងារសម្រាប់ការិយាល័យស្រុកប្រតិបត្តិ និង (៤) ក្របខ័ណ្ឌស្នាដៃការងារសម្រាប់ការិយាល័យមន្ទីរសុខាភិបាលខេត្ត ។

ថវិកាផ្សារភ្ជាប់ស្នាដៃការងារ នៃមូលនិធិសម្រាប់ផ្តល់សេវា (SDGs) នឹងត្រូវបានផ្តល់ទៅឱ្យមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ការិយាល័យស្រុកប្រតិបត្តិ និងការិយាល័យមន្ទីរសុខាភិបាល ។ ស្នាដៃការងារនឹងត្រូវផ្ទៀងផ្ទាត់ប្រចាំត្រីមាសនីមួយៗដោយអ្នកវាយតម្លៃផ្ទៀងផ្ទាត់មកពីការិយាល័យស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាលខេត្ត ។ ការវាយតម្លៃមុនដំបូង (Ex-ante assessment) មានន័យថាជាការវាយតម្លៃនៅមុនពេលស្នាដៃការងារ ត្រូវបានទូទាត់ ហើយយន្តការនៃការវាយតម្លៃនេះនឹងប្រើប្រាស់ការវាយតម្លៃផ្ទៃក្នុង ។ ការផ្ទៀងផ្ទាត់តាមក្រោយពីអ្នកវាយតម្លៃផ្ទៀងផ្ទាត់ខាងក្រៅ (Ex-post verification) នឹងត្រូវធ្វើឡើងដោយភ្នាក់ងារភាគីទីបីដែលត្រូវបានធ្វើការផ្ទៀងផ្ទាត់សម្រាប់គម្រោងមូលនិធិសមធម៌ (HEFs) រហូតដល់យន្តការភាគីទីបីថ្មីមួយគឺភ្នាក់ងារផ្ទៀងផ្ទាត់ការទូទាត់ (PCA) ត្រូវបានបង្កើតឡើង ។ ការផ្ទៀងផ្ទាត់តាមក្រោយពីអ្នកវាយតម្លៃខាងក្រៅ (Ex-post verification) គឺការផ្ទៀងផ្ទាត់បន្ទាប់ពីការទូទាត់សម្រាប់ស្នាដៃការងារត្រូវបានធ្វើរួចហើយ ។ ការវាយតម្លៃផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកានេះនឹងប្រើប្រាស់ពិធីសារចម្រុះ

*ដោយជ្រើសរើសសំណាកដោយចៃដន្យ និងសំណាកផ្អែកលើហានិភ័យ ។ ការដាក់ពិន័យនឹងត្រូវអនុវត្តលើភាពខុសគ្នាដោយអន្ទើដែលមិនអាចពន្យល់បានដែលមានទំហំធំលើសចំណុចកំណត់ពី១០% ឡើងទៅ ដូចបានរៀបរាប់លម្អិតនៅក្នុងផ្នែក បន្ថែមខាងក្រោយ ។ ស្នាដៃការងារនៃមូលនិធិសម្រាប់ផ្តល់សេវា នឹងផ្តោតលើគុណភាពនៃការផ្តល់សេវា តាមរយៈរូបភាពផ្សេងៗ ។ តារាងដាក់ពិន្ទុវាយតម្លៃ នឹងត្រូវបានប្រើនៅគ្រប់កម្រិតទាំងពីរ (មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក) ហើយនឹងវាស់វែងលើ ប្រព័ន្ធដំណើរការ និង លទ្ធផល ជាមួយនឹងការផ្តល់ភាពចាំបាច់ លើការវាស់វែងលើ ក្របខ័ណ្ឌការងារ និងលទ្ធផលការងារ ។ តារាងដាក់ពិន្ទុវាយតម្លៃ ទាំងនេះនឹងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំដោយផ្អែកលើមេរៀនជាបទពិសោធន៍ និងការកើនឡើងនូវភាពប្រសើរនៃការវាស់វែងគុណភាពសេវា ដែលបានលើកក្នុងផែនការសម្រាប់អនុវត្តន៍ ។*

## ៣.១ ភាពញឹកញាប់

*និយមន័យនៃការវាយតម្លៃមុនផ្តល់ថវិកា*–(ex-ante assessments) *និងការវាយតម្លៃផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាពីអ្នកវាយតម្លៃផ្ទៀងផ្ទាត់ពីខាងក្រៅ* (and ex-post verification):

1- *ការវាយតម្លៃមុនផ្តល់ថវិកា៖ គឺជាការវាយតម្លៃដែលធ្វើឡើងមុនពេលធ្វើការទូទាត់ថវិកាស្នាដៃការងារ ។ ការវាយតម្លៃមុនផ្តល់ថវិកា គឺប្រើប្រាស់យន្តការផ្ទៃក្នុង ។*

2- *ការវាយតម្លៃផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកា៖ គឺជាការផ្ទៀងផ្ទាត់ដែលធ្វើឡើងបន្ទាប់ពីការទូទាត់ស្នាដៃការងារបានធ្វើរួចរាល់ ។ ការផ្ទៀងផ្ទាត់តាមក្រោយដោយអ្នកវាយតម្លៃផ្ទៀងផ្ទាត់ពីខាងក្រៅ គឺប្រើប្រាស់យន្តការភាគីទី៣ ។*

*ភាពញឹកញាប់នៃការវាយតម្លៃទាំងនេះគឺធ្វើឡើងប្រចាំត្រីមាស ។ សម្រាប់ការវាយតម្លៃមុនផ្តល់ថវិកានឹងធ្វើការវាយតម្លៃនៅគ្រប់មូលដ្ឋានសុខាភិបាលសាធារណៈទាំងអស់ ក្នុងនេះមានមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ។ សម្រាប់ការផ្ទៀងផ្ទាត់តាមក្រោយដោយអ្នកវាយតម្លៃផ្ទៀងផ្ទាត់ពីខាងក្រៅ ប្រចាំត្រីមាសនីមួយៗ នឹងជ្រើសយកសំណាកគំរូតាមការកំណត់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ ។*

- ***ការវាយតម្លៃមុនផ្តល់ថវិកានៅថ្នាក់មណ្ឌលសុខភាព:*** *ការវាយតម្លៃនៅថ្នាក់មណ្ឌលសុខភាពនឹងត្រូវធ្វើឡើងដោយក្រុមអ្នកវាយតម្លៃមកពីស្រុកប្រតិបត្តិដូចគ្នា ឬក៏មកពីស្រុកប្រតិបត្តិដទៃនៃខេត្តដូចគ្នា ។*

- ***ការវាយតម្លៃមុនផ្តល់ថវិកានៅថ្នាក់មន្ទីរពេទ្យបង្អែកស្រុក (កម្រិត២ ឬ កម្រិត១) :*** *ការវាយតម្លៃនៅថ្នាក់មន្ទីរពេទ្យបង្អែកស្រុក (កម្រិត២ ឬកម្រិត១) នឹងត្រូវធ្វើឡើងដោយក្រុមអ្នកវាយតម្លៃមកពីមន្ទីរសុខាភិបាលខេត្តខ្លួនឯង ឬក៏មកពីមន្ទីរសុខាភិបាលខេត្តផ្សេងៗ ។*
- ***ការវាយតម្លៃមុនផ្តល់ថវិកានៅថ្នាក់មន្ទីរពេទ្យបង្អែកខេត្ត (កម្រិត៣ ឬកម្រិត២):*** *ការវាយតម្លៃនៅថ្នាក់មន្ទីរពេទ្យបង្អែកខេត្ត (កម្រិត៣ ឬ កម្រិត២) នឹងត្រូវធ្វើឡើងដោយក្រុមអ្នកវាយតម្លៃមកពីមន្ទីរសុខាភិបាលខេត្តផ្សេងៗ ។*
- ***ការវាយតម្លៃមុនផ្តល់ថវិកាស្នាដៃការងាររបស់ការិយាល័យស្រុកប្រតិបត្តិ:*** *ស្នាដៃការងាររបស់ការិយាល័យស្រុកប្រតិបត្តិ នឹងត្រូវធ្វើការវាយតម្លៃនៅរៀងរាល់ត្រីមាសនីមួយៗ ដោយក្រុមអ្នកវាយតម្លៃមកពីមន្ទីរសុខាភិបាលខេត្តខ្លួនឯងផ្ទាល់ ។*
- ***ការវាយតម្លៃមុនផ្តល់ថវិកាស្នាដៃការងាររបស់ការិយាល័យមន្ទីរសុខាភិបាលខេត្ត:*** *ស្នាដៃការងាររបស់ការិយាល័យមន្ទីរសុខាភិបាលខេត្ត នឹងត្រូវធ្វើការវាយតម្លៃនៅរៀងរាល់ត្រីមាសនីមួយៗ ដោយក្រុមអ្នកវាយតម្លៃមកពីមន្ទីរសុខាភិបាលនៃខេត្តផ្សេង ។*
- ***ការវាយតម្លៃផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកា*** *ដោយប្រើប្រាស់វិធានចម្រុះនៃសំណាកគំរូជ្រើសរើសដោយចៃដន្យ និងជ្រើសរើសផ្អែកលើហានិភ័យ ដែលនឹងធ្វើឡើងដោយភ្នាក់ងារឯករាជ្យភាគីទី៣ ។ គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិ នឹងត្រូវបង្កើតឡើង និងធ្វើតេស្តក្នុងអំឡុងដំណាក់កាលសាកល្បង ។*

*តារាងទី២៖ ស្ថាប័ន និងការកិច្ចទាក់ទងទៅនឹងការវាយតម្លៃមុនផ្តល់ថវិកា និងការវាយតម្លៃផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកា មកពីខាងក្រៅ*

| ស្ថាប័ន | ការវាយតម្លៃមុនផ្តល់ថវិកា (ការផ្ទៀងផ្ទាត់មុននឹងធ្វើការទូទាត់ចំណាយ) | ការវាយតម្លៃផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាពីអ្នកវាយតម្លៃពីខាងក្រៅ (ការផ្ទៀងផ្ទាត់បន្ទាប់ពីការទូទាត់ចំណាយ) | ភាពញឹកញាប់ (ក្នុង១ត្រីមាស) |
|---|---|---|---|
| មណ្ឌលសុខភាព | អ្នកវាយតម្លៃមកពីការិយាល័យស្រុកប្រតិបត្តិ | ភ្នាក់ងារភាគីទី៣ (២,៥% X ១,១៧៤) = ៣០ មណ្ឌលសុខភាព ដែលត្រូវជ្រើសរើសដោយចៃដន្យ បន្ថែមទៅលើវិធានជ្រើសរើសផ្អែកលើហានិភ័យ[1] / បញ្ហាប្រឈម | • វាយតម្លៃជាមុនប្រចាំត្រីមាស<br>• ផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាប្រចាំត្រីមាស |
| មន្ទីរពេទ្យបង្អែកស្រុក (កម្រិត២ ឬកម្រិត១) | អ្នកវាយតម្លៃមកពីមន្ទីរសុខាភិបាល (ក្នុងខេត្តដូចគ្នា) | ភ្នាក់ងារភាគីទី៣ (១០% X ៧៥) = ៨ មន្ទីរពេទ្យបង្អែកស្រុក ដែលត្រូវជ្រើសរើសដោយចៃដន្យបន្ថែមទៅលើវិធានជ្រើសរើសផ្អែកលើហានិភ័យ/បញ្ហាប្រឈម | • វាយតម្លៃជាមុនប្រចាំត្រីមាស<br>• ផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាប្រចាំត្រីមាស |
| មន្ទីរពេទ្យបង្អែកខេត្ត (កម្រិត៣ ឬកម្រិត២) | អ្នកវាយតម្លៃមកពីមន្ទីរសុខាភិបាល (មកពីខេត្តផ្សេង) | ភ្នាក់ងារភាគីទី៣ (២០% X ២៥) = ៥ មន្ទីរពេទ្យបង្អែកខេត្ត ដែលត្រូវជ្រើសរើសដោយចៃដន្យបន្ថែមទៅលើវិធានជ្រើសរើសផ្អែកលើហានិភ័យ/បញ្ហាប្រឈម | • វាយតម្លៃជាមុនប្រចាំត្រីមាស<br>• ផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាប្រចាំត្រីមាស |

[1] ករណីដែលសង្ស័យថាមានភាពមិនប្រក្រតី

| ស្ថាប័ន | ការវាយតម្លៃមុនផ្តល់ថវិកា (ការផ្ទៀងផ្ទាត់មុននឹងធ្វើការទូទាត់ចំណាយ) | ការវាយតម្លៃផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាពីអ្នកវាយតម្លៃពីខាងក្រៅ (ការផ្ទៀងផ្ទាត់បន្ទាប់ពីការទូទាត់ចំណាយ) | ភាពញឹកញាប់ (ក្នុង១ត្រីមាស) |
|---|---|---|---|
| ការិយាល័យស្រុកប្រតិបត្តិ | អ្នកវាយតម្លៃមកពីមន្ទីរសុខាភិបាល (ក្នុងខេត្តដូចគ្នា) | ភ្នាក់ងារភាគីទី៣ (១០% X ៩២) = ៩ ការិយាល័យស្រុកប្រតិបត្តិ ដែលត្រូវជ្រើសរើសដោយចៃដន្យបន្ថែមទៅលើវិធានជ្រើសរើសផ្អែកលើហានិភ័យ/បញ្ហាប្រឈម | • វាយតម្លៃជាមុនប្រចាំត្រីមាស<br>• ផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាប្រចាំត្រីមាស |
| ការិយាល័យមន្ទីរសុខាភិបាលខេត្ត | អ្នកវាយតម្លៃមកពីមន្ទីរសុខាភិបាល (មកពីខេត្តខេត្តផ្សេង) | ភ្នាក់ងារភាគីទី៣ (២៥% X ២៥) = ៥ ការិយាល័យមន្ទីរសុខាភិបាលខេត្ត ដែលត្រូវជ្រើសរើសដោយចៃដន្យបន្ថែមទៅលើវិធានជ្រើសរើសផ្អែកលើហានិភ័យ/បញ្ហាប្រឈម | • វាយតម្លៃជាមុនប្រចាំត្រីមាស<br>• ផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាប្រចាំត្រីមាស |

## ៣.២ សមាសភាពក្រុមអ្នកវាយតម្លៃដែលមានវិញ្ញាបនប័ត្រ

## មណ្ឌលសុខភាព៖ អ្នកវាយតម្លៃ២នាក់មកពីស្រុកប្រតិបត្តិ

- o វេជ្ជបណ្ឌិត ឬគិលានុប្បដ្ឋាកមធ្យម ១នាក់និង
- o ឆ្មបមធ្យម១នាក់

- **មន្ទីរពេទ្យបង្អែកស្រុក** (កម្រិត២ ឬកម្រិត១): អ្នកវាយតម្លៃផ្ទៀងផ្ទាត់ចំនួន៤នាក់
  - o វេជ្ជបណ្ឌិតចំនួន២នាក់
  - o ឆ្មបមធ្យម១នាក់
  - o គិលានុប្បដ្ឋាកមធ្យម១នាក់
- **មន្ទីរពេទ្យបង្អែកខេត្ត** (កម្រិត៣ ឬកម្រិត២): អ្នកវាយតម្លៃផ្ទៀងផ្ទាត់មកពីមន្ទីរសុខាភិបាល ចំនួន៦នាក់
  - o វេជ្ជបណ្ឌិតចំនួន៣នាក់
  - o ឱសថការី (ផ្នែកមន្ទីរពិសោធន៍/ឱសថការី) ១នាក់
  - o ឆ្មប១នាក់
  - o គិលានុប្បដ្ឋាក១នាក់
- **ការិយាល័យស្រុកប្រតិបត្តិ:** អ្នកវាយតម្លៃផ្ទៀងផ្ទាត់២នាក់មកពីខេត្តដូចគ្នា
- **ការិយាល័យមន្ទីរសុខាភិបាលខេត្ត:** អ្នកវាយតម្លៃផ្ទៀងផ្ទាត់២នាក់មកពីខេត្តផ្សេងគ្នា

## ៣.៣ ពេលវេលានៃការវាយតម្លៃ និងការបង្វឹក

ការវាយតម្លៃគួរត្រូវធ្វើឡើងឲ្យបានចប់សព្វគ្រប់នៅក្នុងអំឡុងពេល១ខែ នៃចុងត្រីមាសបន្តបន្ទាប់ៗ ឧទាហរណ៍ ត្រីមាសទី១នៃឆ្នាំចាប់ផ្តើមពីខែមករាដល់ខែមិនា ការផ្ទៀងផ្ទាត់គួរត្រូវបញ្ចប់នៅចុងខែមេសា ។ ហើយជុំទីមួយៗនៃការបំពេញបន្ថែម ឬការតាមដានការបង្វឹកគួរត្រូវធ្វើឡើងក្នុងអំឡុងខែបន្តបន្ទាប់នៃការវាយតម្លៃមុនផ្តល់ថវិកា និងបន្ទាប់ពីជុំនៃការបង្វឹកលើកទី១ ។ អ្នកវាយតម្លៃដែលមានវិញ្ញាបនប័ត្រស្រុកប្រតិបត្តិនឹងធ្វើការបង្វឹកបុគ្គលិកមណ្ឌលសុខភាព ហើយអ្នកវាយតម្លៃដែលមានវិញ្ញាបនប័ត្រមន្ទីរសុខាភិបាលនឹងធ្វើការបង្វឹកទៅដល់បុគ្គលិកមន្ទីរពេទ្យបង្អែក (កម្រិត១, កម្រិត២, និងកម្រិត៣) ។

## ៣.៤ ការចងក្រងលទ្ធផល និងការផ្តល់សំណង

ទិន្នន័យនឹងត្រូវទាញចេញពីកុំព្យូទ័រស្តើង (tablets) ដាក់បញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋានអនឡាញ (online database) មួយ ។ ឯកសារសង្ខេប១សន្លឹកនៃលទ្ធផលសម្រាប់ការផ្ទៀងផ្ទាត់នីមួយៗនឹងត្រូវរក្សាទុកនៅស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាលខេត្តសម្រាប់គោលបំណងផ្នែករដ្ឋបាល ។ ទិន្នន័យដែលត្រូវបានសម្អាតដោយនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល និងបង្ហាញទៅក្រុមការងារលើកកម្ពស់គុណភាពសេវាតាមត្រីមាសនីមួយៗ សម្រាប់សុពលភាព និងការអនុម័តដោយនាយកគម្រោង ។

## ៣.៥ ការផ្តល់វិញ្ញាបនប័ត្រដល់អ្នកវាយតម្លៃដើម្បីពង្រឹងលទ្ធផល

អ្នកវាយតម្លៃនៃស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាល គឺជាធាតុសំខាន់មួយនៃកម្មវិធីលើកកម្ពស់គុណភាពថ្នាក់ជាតិ ដែលនេះជាមូលហេតុដែលពួកគេត្រូវទទួលបានការបណ្តុះបណ្តាល និងការផ្តល់វិញ្ញាបនប័ត្រដើម្បីអនុវត្តការកិច្ចថ្មីទាំងនេះបានល្អ ។ នៅចុងបញ្ចប់នៃកម្មវិធីបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃ ដែលនឹងមានការធ្វើតេស្តមុន និង ក្រោយការបណ្តុះបណ្តាល ដែលរួមបញ្ចូលទាំងការអនុវត្តន៍ជាក់ស្តែងនៅតាមមូលដ្ឋានសុខាភិបាលផង អ្នកវាយតម្លៃនឹងទទួលបានវិញ្ញាបនប័ត្រ សម្រាប់ការវាយតម្លៃគុណភាពមុនដំបូង (ex-ante quality assessments) ។ អ្នកវាយតម្លៃមានវិញ្ញាបនប័ត្រ នឹងត្រូវបង្វឹក និងទទួលបានការណែនាំពីក្រុមថ្នាក់កណ្តាល ដែលមានក្រុមការងារលើកកម្ពស់គុណភាពនៃក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍ ។ កម្មវិធីបង្វឹក និងការណែនាំនេះ នឹងត្រូវបង្កើតឡើង ដែលនឹងពង្រឹងនូវសមត្ថភាពអ្នកវាយតម្លៃ ដើម្បីអនុវត្តមុខងាររបស់ពួកគេ ដើម្បីផ្តល់នូវព័ត៌មានត្រឡប់គ្រប់ជ្រុងជ្រោយទៅអ្នកផ្តល់សេវាសុខភាព និងដើម្បីរក្សានូវការអភិវឌ្ឍន៍ទាន់កាលៈទេសៈនៅក្នុងមូលដ្ឋានរបស់ពួកគេ ។ អ្នកវាយតម្លៃសម្រាប់ធ្វើការផ្ទៀងផ្ទាត់តាមក្រោយ នឹងត្រូវបានទទួលការបណ្តុះបណ្តាល និងចេញវិញ្ញាបនប័ត្រដោយគ្រូថ្នាក់ជាតិដូចគ្នា ដែលជាអ្នកផ្តល់ការបណ្តុះបណ្តាល និងចេញវិញ្ញាបនប័ត្របញ្ជាក់ដល់អ្នកវាយតម្លៃសម្រាប់ធ្វើការវាយតម្លៃមុនផ្តល់ថវិកា (ex-ante assessments) ។

## ៣.៦ ឧបករណ៍តាមដានកែលម្អគុណភាពថ្នាក់ជាតិ

ឧបករណ៍នេះ នឹងត្រូវប្រើប្រាស់ដោយអ្នកវាយតម្លៃផ្ទៀងផ្ទាត់សម្រាប់ការវាយតម្លៃមុនផ្តល់ថវិកា។

ឧបករណ៍សម្រាប់ថ្នាក់មណ្ឌលសុខភាពរួមមានៈ

(1) តារាងដាក់ពិន្ទុវាយតម្លៃមណ្ឌលសុខភាព (BSC-HC)
(2) ឧបករណ៍សន្ទស្សន៍៖ ជាក្រដាស់ឯកសារសម្រាប់មណ្ឌលសុខភាព
(3) ការវាយតម្លៃស្នាដៃការងារជាលក្ខណៈបុគ្គលសម្រាប់បុគ្គលិកមណ្ឌលសុខភាព
(4) ករណីសិក្សាគ្លីនីកដែលបានជ្រើសនិងកែសម្រួលពីឧបករណ៍វាយតម្លៃកម្រិត២
(5) បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការសង្កេតការសង្គ្រោះទារក
(6) ព័ត៌មានត្រឡប់ពីការថែទាំពីការអង្កេតអំពីការពេញចិត្តរបស់អតិថិជននៃសហគមន៍

ការវាយតម្លៃផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាពីអ្នកវាយតម្លៃពីខាងក្រៅ នឹងប្រើប្រាស់ឧបករណ៍ដូចគ្នា លើកលែងតែព័ត៌មានត្រឡប់ពីការថែទាំពីការអង្កេតអំពីការពេញចិត្តរបស់អតិថិជននៃសហគមន៍។

ឧបករណ៍សម្រាប់មន្ទីរពេទ្យបង្អែក (កម្រិត១ កម្រិត២ និង កម្រិត៣) រួមមាន៖

(1) តារាងដាក់ពិន្ទុវាយតម្លៃសម្រាប់មន្ទីរពេទ្យ មាន៣ប្រភេទ គឺសម្រាប់មន្ទីរបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣
(2) ឧបករណ៍សន្ទស្សន៍៖ ជាឯកសារ MS Excel សម្រាប់មន្ទីរពេទ្យ
(3) ការវាយតម្លៃស្នាដៃការងារជាលក្ខណៈបុគ្គលសម្រាប់បុគ្គលិកមន្ទីរពេទ្យ
(4) ករណីសិក្សាគ្លីនីកដែលបានជ្រើសនិងកែសម្រួលពីឧបករណ៍វាយតម្លៃកម្រិត២
(5) បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការសង្កេតការសង្គ្រោះទារក
(6) ព័ត៌មានត្រឡប់ស្តីពីការថែទាំពីការអង្កេតអំពីការពេញចិត្តរបស់អតិថិជននៃសហគមន៍

ឧបករណ៍សម្រាប់ការិយាល័យស្រុកប្រតិបត្តិនិងការិយាល័យមន្ទីរសុខាភិបាលខេត្ត រួមមាន៖

(1) ក្របខ័ណ្ឌស្នាដៃការងារសម្រាប់ការិយាល័យស្រុកប្រតិបត្តិ
(2) ក្របខ័ណ្ឌស្នាដៃការងារសម្រាប់ការិយាល័យមន្ទីរសុខាភិបាលខេត្ត

ការស្ទង់មតិលើការពេញចិត្តរបស់អតិថិជនក្នុងសហគមន៍ នឹងផ្តល់ព័ត៌មានលើសេវាជាក់លាក់នៃអត្តចរិកលក្ខណៈសេវាថែទាំសុខភាព ដែលនឹងត្រូវដាក់បញ្ចូលគ្នាជាមួយនឹងពិន្ទុគុណភាពរបស់មូលដ្ឋានសុខាភិបាល ។ ការស្ទង់មតិនេះនឹងត្រូវធ្វើឡើងជាប្រព័ន្ធដោយអ្នកវាយតម្លៃ

ដែលមានវិញ្ញាបនប័ត្រក្នុងអំឡុងនៃការវាយតម្លៃមុនផ្តល់ថវិកា ។ អ្នកទទួលផលនឹងត្រូវជួបសម្ភាសន៍តាមរយៈការជ្រើសរើសសំណាកគំរូដោយចៃដន្យជាប្រព័ន្ធនៃការចុះឈ្មោះអ្នកជម្ងឺ ហើយការសម្ភាសន៍ពីមតិយោបល់របស់ពួកគេទាក់ទងទៅនឹងការផ្តល់សេវា លើការចំណាយប្រាក់ពីហោប៉ៅពួកគេ នឹងត្រូវបានសួរបន្ថែមទៀតផងដែរទៅតាមចំនួនជាក់ស្តែងនៃមាតិការក្នុងសំណួរ ។

បន្ទាប់មកទៀត មាតិកានៃសំណួរលើសេវាថែទាំសុខភាព នឹងត្រូវប្រើប្រាស់ដើម្បីបង្រ្គប់ការវាយតម្លៃនៃតារាងដាក់ពិន្ទុវាយតម្លៃ (BSC) ។ បន្ថែមលើនេះ មតិយោបល់នៃអ្នកទទួលផល និងការយល់ឃើញរបស់ពួកគេពីលទ្ធផលនៃសេវាសុខភាព បន្ថែមលើលទ្ធផលដែលបានមកពីការតាមដានការថែទាំសុខភាព នឹងត្រូវបានកំណត់ជាបរិមាណ និងយកមកពិចារណានៅពេលទូទាត់ការចំណាយដល់អ្នកផ្តល់សេវា តាមរយៈមូលនិធិសម្រាប់ផ្តល់សេវា (SDGs) ។ ដំណើរការនៃការស្ទង់មតិការពេញចិត្តរបស់អតិថិជនក្នុងសហគមន៍នេះ ត្រូវបានគេហៅថា "ការផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាពីអ្នកវាយតម្លៃពីខាងក្រៅ" ។ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) សម័យទំនើប នឹងត្រូវប្រើប្រាស់ (ដូចជាឧបករណ៍ប្រព័ន្ធប្រតិបត្តិការ Android ដែលមានតម្លៃទាប) ជាមួយនឹងការបញ្ជូនទិន្នន័យដោយស្វ័យប្រវត្តិទៅក្នុងមូលដ្ឋានទិន្នន័យដែលភ្ជាប់នឹងអ៊ិនធើនែតឬកុំព្យូទ័រ (អនឡាញ)មួយ ។ ខ្លឹមសារនៃឧបករណ៍និងវិធាននៃការចំណាយនឹងត្រូវធ្វើការផ្លាស់ប្តូរជាទៀងទាត់ ។

## ៣.៧ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ( ICT )

បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) នឹងមានសារៈសំខាន់សម្រាប់កម្មវិធីលើកកម្ពស់គុណភាពសេវា ។ ការងារនេះមានៈ៖ (១) កម្មវិធីគេហ៍ទំព័រ (web-based application) មួយដែល ខទំព័រខាងមុខមានបង្ហាញជាសាធារណៈអំពីលទ្ធផលស្នាដៃការងារ (២) កម្មវិធីផ្នែកទន់ (software) សម្រាប់ការដាក់ពិន្ទុវាយតម្លៃ រួមទាំងមានកូនរូបភាព និងការវាយតម្លៃផ្អែកលើសមត្ថភាព និង (៣) អាចនឹងមានការប្រើប្រាស់កុំព្យូទ័របន្ទះស្តើង (tablet) ឬ កម្មវិធីលើស្មាតហ្វូន ដែលនឹងត្រូវប្រើក្នុងកំឡុងពេលនៃការស្ទង់មតិអំពីការពេញចិត្តរបស់អតិថិជននៅសហគមន៍ ។

ទិន្នន័យនឹងត្រូវរក្សាទុកនៅក្នុងកុំព្យូទ័របន្ទះស្តើង និង/ឬ ទូរស័ព្ទស្មាតហ្វូន និងដាក់បញ្ចូល (អាប់ឡូត) តាមរយៈបណ្តាញទិន្នន័យចល័ត (4G/3G/EDGE) ឬវៃហ្វាយ (Wifi) ។ កម្មវិធីនៅក្នុងកុំ

ព្យូទ័របន្ទះស្មើង និង/ឬ ទូរស័ព្ទស្មាតហ្វូន នឹងប្រមូលព័ត៌មានគោលសំខាន់ៗ (Meta data)ដូចជាទីតាំងភូមិសាស្ត្រនិងពេលវេលា ដែលមានតម្លៃសម្រាប់ការវាយតម្លៃតាមដាន។

ម៉ូឌុលគ្រប់គ្រងសម្រាប់នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល នឹងមានផ្ទៃតាប្លូសម្រាប់តាមដានស្នាដៃការងារ និងទម្រង់របាយការណ៍ស្វ័យប្រវត្តិផ្សេងៗ ។ ម៉ូឌុលសម្រាប់ការទូទាត់ចំណាយ ត្រូវបានគ្រប់គ្រងផងដែរដោយនាយកដ្ឋានសេវាមន្ទីរពេទ្យ ។

ទិន្នន័យមូលដ្ឋានគួរតែត្រូវបានរក្សាទុកនៅនាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាល (DPHI) ជាទិន្នន័យមូលដ្ឋានរបស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងសុខាភិបាល (HMIS) ផងដែរ ។

## ៣.៨ សេចក្តីណែនាំប្រចាំឆ្នាំរបស់នាយកគ្រប់គ្រងគម្រោង

សេចក្តីណែនាំពីនាយកគម្រោង ផ្តល់ព័ត៌មានដល់មូលដ្ឋានសុខាភិបាលទាំងអស់ អំពីយន្តការជាតិតាមដានការបង្កើនគុណភាពប្រចាំឆ្នាំ រួមទាំងដំណើរការសម្រាប់ឆ្លើយន្តការជាតិតាមដានការបង្កើនគុណភាព តួនាទី និងភារកិច្ចរបស់មូលដ្ឋានសុខាភិបាល អត្រាការទូទាត់ចំណាយអតិបរមា លក្ខណៈវិនិច្ឆ័យ និងដំណើរការនៃការទូទាត់ចំណាយជាដើម។ ការណែនាំនេះនឹងត្រូវបានព្រាងក្នុងការពិគ្រោះយោបល់ជាមួយនឹងក្រុមការងារយន្តការជាតិតាមដានការបង្កើនគុណភាព និង ត្រូវផ្សព្វផ្សាយទូលំទូលាយទៅដល់មូលដ្ឋានសុខាភិបាលទាំងអស់ក្នុងអំឡុងខែមករារៀងរាល់ឆ្នាំ ។

# ៤. ការចំណាយដែលអាចទូទាត់បាន

កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល ត្រូវបានបម្រុងទុកជាថវិកាបន្ថែម ទៅលើថវិកាប្រតិបត្តិការរបស់មូលដ្ឋានសុខាភិបាល ដើម្បីគ្រប់គ្រង និងអនុវត្តការចំណាយដោយផ្ទាល់ក្នុងបំណងដើម្បីលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល ។ កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាលនេះ មិនអាចប្រើសម្រាប់ការលើកទឹកចិត្តបុគ្គលិកបានទេ ។

ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ ត្រូវបានបម្រុងទុកដើម្បីផ្តល់រង្វាន់ដល់មូលដ្ឋានសុខាភិបាលសម្រាប់ស្នាដៃការងារដែលមានគុណភាព ។ ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារនេះត្រូវបានបម្រុងទុកផងដែរសម្រាប់ផ្តល់រង្វាន់ដល់ ការិយាល័យស្រុកប្រតិបត្តិ និង មន្ទីរសុខាភិបាលរាជធានី ខេត្ត និងជាពិសេស និងជាពិសេសសម្រាប់ក្រុមអ្នកវាយតម្លៃដើម្បីចំណាយក្នុងការវាយតម្លៃគុណភាព

សេវា ។ ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ អាចចំណាយបានសម្រាប់ការលើកទឹកចិត្តបុគ្គលិកមិនឲ្យលើសពី ៨០% ។ យ៉ាងតិចបំផុត ២០% នៃថវិកាផ្សារភ្ជាប់ស្នាដៃការងារ (អាស្រ័យលើការប្រើប្រាស់ដែលជាចំណែកសល់ពីការលើកទឹកចិត្ត) មានសិទ្ធិចាយលើចំណាយផ្សេងៗទៀតដែលមានបរិយាយនៅក្នុងតារាងនៃផ្នែក៤.១ ។

ក្នុងករណីដែលអ្នកផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាពីអ្នកវាយតម្លៃពីខាងក្រៅរកឃើញថារបាយការណ៍មានភាពមិនត្រឹមត្រូវ ទោះជាចេតនា ឬដោយអចេតនាក៏ដោយ សូមមើលផ្នែកទី៦ អំពីរបាយការណ៍មិនត្រឹមត្រូវ សម្រាប់ការចំណាយដែលមានសិទ្ធិធ្វើ នៃថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារដែលនៅសេសសល់ពីការកាត់ទុក ។

## ៤.១ ប្រភេទចំណាយនៃមូលនិធិសម្រាប់ផ្តល់សេវាដែលអាចទូទាត់បាន

ដោយផ្អែកលើការវាយតម្លៃ គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល (SDG) ប្រកាសអន្តរក្រសួង លេខ ៣០២សហវ/ប្រក ចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាលនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០១៦ និងសេចក្តីណែនាំលេខ ៦៣២សនថហ ចុះហត្ថលេខាដោយក្រសួងសុខាភិបាលនៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៦ ប្រភេទចំណាយដែលអាចចាយបាននៃមូលនិធិសម្រាប់ផ្តល់សេវា រួមមាន៖

*តារាងទី ២ តារាងនៃការចំណាយដែលអាចទូទាត់បាន ប្រើប្រាស់មូលនិធិសម្រាប់ផ្តល់សេវា*

| លេខ | តារាងសិទ្ធទទួលបានការចំណាយ | កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល | ថវិកាផ្សារភ្ជាប់ស្នាដៃការងារ |
|---|---|---|---|
| I. | ចំណាយចរន្តចាំបាច់សម្រាប់ការងាររដ្ឋបាល | | |
| | សម្ភារៈការិយាល័យ | | |
| ១ | ថតចម្លង និងបោះពុម្ព | X | X |

| | | | |
|---|---|---|---|
| ២ | កាតទូរស័ព្ទសម្រាប់ការវាយតម្លៃការពេញចិត្តរបស់អតិថិជន | | X |
| | ការជួសជុល និងថែទាំតូចតាច | | |
| ៣ | ឡដុតសម្រាម | X | X |
| ៤ | សម្ភារៈមន្ទីរពិសោធន៍ និងវេជ្ជសាស្ត្រ | X | X |
| | អនាម័យ | | |
| ៥ | ថង់ផ្លាស្ទិក អំបោស ធុងសំរាមស្តង់ដា (លឿង បៃតង...) ធុងដាក់ទឹក ប្រដាប់សម្អាតឥដ្ឋការ៉ូ | X | X |
| ៦ | សាប៊ូលាងដៃ សាប៊ូបោកខោអាវ សារធាតុសម្លាប់មេរោគ អាល់កុល ក្រដាសជូតដៃ កន្សែងពោះគោ ធុងទឹក | X | X |
| ៧ | ការដឹកជញ្ជូន និងការកំទេចចោលកាកសំណល់វេជ្ជសាស្ត្រ (សម្រាប់តែមណ្ឌលសុខភាពប៉ុណ្ណោះ) | X | X |
| II. | ការចំណាយសម្រាប់ការសង្គ្រោះបន្ទាន់ | | |
| ៨ | ប្រេងសាំងសម្រាប់រថយន្តសង្គ្រោះបន្ទាន់ និង | X | X |
| ៩ | មធ្យោបាយផ្សេងទៀតសម្រាប់ករណីបញ្ជូនបន្ទាន់ | X | X |
| III. | ការបញ្ជាទិញបន្ទាន់សម្រាប់ឱសថ សម្ភារៈវេជ្ជសាស្ត្រ និង សម្ភារៈប្រើប្រាស់ | | |
| ១០ | ហ្គាសសម្រាប់ប្រព័ន្ធត្រជាក់ (ទូរទឹកកក) | X | X |
| ១១ | សម្ភារៈប្រើប្រាស់វេជ្ជសាស្ត្រ (សំឡី បង់រុំ ស៊ីរ៉ាំង...) | X | X |

| | | | |
|---|---|---|---|
| ១២ | ឱសថតម្រូវការបន្ទាន់ និងដែលបានដាច់ស្តុក ពីខ្សែចង្វាក់ប្រព័ន្ធផ្គត់ផ្គង់ជម្មតា | X | X |
| ១៣ | សម្ភារៈតូចតាចសម្រាប់ថែទាំអ្នកជំងឺ (ប្រដាប់តេស្តជាតិស្ករក្នុងឈាម តេស្តជាតិស្ករក្នុងទឹកនោម/ប្រូតេអ៊ីន/ប៉េហាស់) | X | X |
| ១៤ | ប្រតិករ (Reagent) នៅពេលដែលមិនមានការផ្គត់ផ្គង់តាមប្រព័ន្ធជម្មតា | X | X |
| IV. | **សកម្មភាពផ្សព្វផ្សាយ និងវិធានការផ្សេងៗទៀតដើម្បីកែលម្អគុណភាពនៃការផ្តល់សេវាសុខភាព** | | |
| ១៥ | ការលើកទឹកចិត្តបុគ្គលិកផ្អែកលើស្នាដៃការងារ | | X |
| ១៦ | ប្រាក់ហោប៉ៅ (per-diems) ថ្ងៃស្នាក់នៅ និងសោហ៊ុយធ្វើដំណើរ | | X |

មូលនិធិសម្រាប់ផ្តល់សេវា អាចត្រូវបម្រុងទុកសម្រាប់ជាថវិកាលើកទឹកចិត្តដល់បុគ្គលិកតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់នៃការប្រើប្រាស់ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ នៅក្នុងផ្នែកនៃការបែងចែកមូលនិធិសម្រាប់ផ្តល់សេវានេះ ។ ថវិកាលើកទឹកចិត្តផ្សារភ្ជាប់នឹងស្នាដៃការងារ នៃមូលនិធិសម្រាប់ផ្តល់សេវា (SDG) ជាផ្នែកមួយនៃការលើកទឹកចិត្តបុគ្គលិកសរុបនៃមូលដ្ឋានសុខាភិបាល (ដែលរួមមាន ៦០% នៃប្រាក់ចំណូលពីការបង់ថ្លៃសេវាដោយអ្នកជំងឺ ផ្ទាល់ ប្រាក់ដែលទទួលបានពីការបង់ថ្លៃនៃគម្រោងមូលនិធិសមធម៌ ប្រាក់ទទួលបានពីគម្រោងធានារ៉ាប់រងសុខភាពសហគមន៍ និងពីប្រភពផ្សេងទៀតនៃសេវាហិរញ្ញប្បទាន ព្រមទាំងប្រាក់រង្វាន់ផ្សារភ្ជាប់ស្នាដៃការងារនៃមូលនិធិសម្រាប់ផ្តល់សេវា) ។

# ៥. វិធានការរដ្ឋបាលត្រូវអនុវត្តសម្រាប់ការធ្វើរបាយការណ៍មិនត្រឹមត្រូវ

## ៥.១ របាយការណ៍មិនត្រឹមត្រូវ

*សេចក្តីណែនាំនៃការផ្តល់ហិរញ្ញប្បទានផ្សារភ្ជាប់ស្នាដៃការងារ (PBF) បង្កើនហានិភ័យនៃការធ្វើរបាយការណ៍មិនត្រឹមត្រូវ ដោយសារ អ្នកផ្តល់សេវាមួយចំនួន ឬ បុគ្គលិករដ្ឋបាល អាចនឹងបំប៉ោងលទ្ធផលដើម្បីបានប្រាក់បន្ថែម ។ នីតិវិធីនៃការផ្ទៀងផ្ទាត់ និងការផ្ទៀងផ្ទាត់ឡើងវិញ កាត់បន្ថយកំហុសទាំងនេះ តាមរយៈការវាស់វែងពីភាពខុសគ្នារវាងការស្នើសុំការទូទាត់ (និងការបង់ប្រាក់ទូទាត់) លើស្នាដៃការងារ និងការអនុវត្តជាក់ស្តែង ។ កិច្ចការនេះតម្រូវឱ្យមានការយកចិត្តទុកដាក់ជាពិសេស និងមានវិធានការដើម្បីរកឱ្យឃើញនូវកំហុស និងការដាក់ទណ្ឌកម្ម ក្នុងករណីដែលការផ្ទៀងផ្ទាត់ឃើញថាមានកំហុស ។*

*របាយការណ៍មិនត្រឹមត្រូវនៅក្នុងប្រព័ន្ធនៃការផ្តល់ហិរញ្ញប្បទានផ្សារភ្ជាប់ស្នាដៃការងារ អាចជាចេតនា ឬអចេតនា ។ កំហុសដោយចេតនាពាក់ព័ន្ធនឹងការក្លែងបន្លំឯកសារដែលទាក់ទងទៅនឹងសកម្មភាពសេវាកម្ម ក្លែងបន្លំព័ត៌មានចុះក្នុងបញ្ជី ការដាក់របាយការណ៍ចំពោះសេវាដែលមិនបានផ្តល់ ការបញ្ជូនអ្នកជំងឺទៅទទួលការថែទាំដែលអ្នកប្រើប្រាស់សេវាមិនបានទទួលផលប្រយោជន៍ជាដើម ។*

*ការធ្វើរបាយការណ៍មិនត្រឹមត្រូវកើតឡើងជាមួយនឹងការស្នើសុំទូទាត់ថ្លៃសេវា ប៉ុន្តែក៏កើតឡើងផងដែរជាមួយនឹងការវាយតម្លៃគុណភាព ។ កំហុសដោយអចេតនា ( ដែលកើតឡើងដោយកម្រ) អាចជាកំហុសដែលកើតមានឡើងដោយអ្នកវាយតម្លៃ ដោយសារតែខ្វះការយល់ដឹងគ្រប់ជ្រុងជ្រោយនៃសូចនាករនៅលើបញ្ជីផ្ទៀងផ្ទាត់គុណភាព ឬ អាចជាការបកស្រាយមិនត្រឹមត្រូវនៃសូចនាករដោយអ្នកវាយតម្លៃផ្សេងគ្នា (ផលប៉ះពាល់នេះដែលគេហៅថា "ការប្រែប្រួលអន្តរៈអ្នកសង្កេតការណ៍" ) ។*

*ដើម្បីជៀសវាងការធ្វើរបាយការណ៍មិនត្រឹមត្រូវ ទោះបីជាមានចេតនា ឬអចេតនាក៏ដោយ តម្រូវឲ្យមានការផ្តល់ការលើកទឹកចិត្តសម្រាប់ឥរិយាបថល្អ ការធ្វើរបាយការណ៍ត្រឹមត្រូវ និងការផ្តល់ពិន្ទុត្រឹមត្រូវ រួមនិងការកាត់ថវិកាលើកទឹកចិត្តសម្រាប់ការអនុវត្តមិនបានត្រឹមត្រូវ ឬមានកំហុស ។ ក្នុងគ្រប់ករណីទាំងអស់ របាយការណ៍ដែលមិនត្រឹមត្រូវ អាចនឹងត្រូវឲ្យមានការពន្យល់*

ដោយបង្ហាញភស្តុតាងដែលអាចជឿទុកចិត្តបាន (ចំនួន និងអង្គហេតុ) ប៉ុន្តែត្រូវឲ្យមានគុណភាពផងដែរ (របាយការណ៍ពន្យល់ជាលាយលក្ខណ៍អក្សរ នូវរឿងរ៉ាវអ្វីដែលបានកើតឡើងជាក់ស្តែង) ដោយសារពេលខ្លះករណីនៃកំហុសអចេតនាមួយ អាចត្រូវបានផ្អែកលើការបកស្រាយខុសនៃធាតុមួយរបស់បញ្ជីផ្ទៀងផ្ទាត់សម្រាប់ត្រួតពិនិត្យគុណភាព ឧបមាថា ការជ្រើសរើសខុសនូវសំណាកគំរូនៃសំណុំឯកសាររបស់អ្នកជំងឺផ្សេងគ្នា ឬក៏ដោយសារ ការបកស្រាយផ្សេងគ្នានៃព្រឹត្តិការណ៍ដូចគ្នាចំពោះអ្នកវាយតម្លៃផ្សេងគ្នា ។ ទោះជាយ៉ាងណា នៅពេលដែលរបាយការណ៍មិនត្រឹមត្រូវមួយត្រូវបានបង្កើតឡើងដោយផ្អែកលើភស្តុតាងដែលជាបរិមាណ និងគាំទ្រដោយសមាសធាតុគុណភាព គួរមានការដាក់ទណ្ឌកម្មខ្លាំងក្លាដើម្បីកុំឱ្យមានការប្រព្រឹត្តខុសនាពេលអនាគត ។

ក្នុងករណីនៃការផ្ទៀងផ្ទាត់ឡើងវិញ (ឬការវាយតម្លៃផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាពីអ្នកវាយតម្លៃពីខាងក្រៅ) រកឃើញថាពិន្ទុខ្ពស់ជាងការវាយតម្លៃផ្តល់ថវិកា ដូច្នេះក្នុងករណីនេះលទ្ធផលជាក់ស្តែងពីអ្នកវាយតម្លៃមុននឹងត្រូវរក្សាទុកដដែល ។ មូលហេតុ គឺថាការធ្វើតេស្តសមត្ថភាព និងចំណេះដឹងមូលដ្ឋានដែលធ្វើនៅពេលមុន និងរយៈពេលមួយក្រោយទៀត នាំឲ្យមានការកើនឡើងនូវស្នាដៃការងារ ដូច្នេះហើយលទ្ធផលនៃការផ្ទៀងផ្ទាត់ឡើងវិញ អាចខ្ពស់ជាងលទ្ធផលនៃការវាយតម្លៃមុនផ្តល់ថវិកា ។ ទោះជាយ៉ាងណា នៅក្នុងករណីនៃការផ្ទៀងផ្ទាត់ឡើងវិញបានរកឃើញថា **ពិន្ទុទាបជាងការវាយតម្លៃមុនដំបូង** ក្នុងករណីនេះលទ្ធផលនៃការផ្ទៀងផ្ទាត់ឡើងវិញនឹងត្រូវរក្សាទុកជាបានការ ។

## ៥.២ ការកាត់បន្ថយហានិភ័យ និងការគ្រប់គ្រងផ្ទៃក្នុង

វិធាននៃការបង្ការដូចខាងក្រោមត្រូវអនុវត្តដើម្បីកាត់បន្ថយហានិភ័យ នៃការធ្វើរបាយការណ៍មិនត្រឹមត្រូវដោយចេតនា ឬ អចេតនាៈ

- ការបែងចែកមុខងារ ដែលអាចជួយកាត់បន្ថយនូវការប្រព្រឹត្តមិនត្រឹមត្រូវដោយចៀសវាងនូវទំនាស់ផលប្រយោជន៍
- ការវាយតម្លៃមុនផ្តល់ថវិកា ដែលអាចជឿទុកចិត្តបាន
- សេចក្តីណែនាំច្បាស់លាស់និងការបណ្តុះបណ្តាលល្អស្ថិតនៅក្នុងច្បាប់នៃការអនុវត្តការងារ

- *ប្រសិទ្ធិភាពប្រព័ន្ធផ្តល់រង្វាន់ និងការដាក់ពិន័យ (និងការអនុវត្តការដាក់ពិន័យក្នុងករណីនៃការផ្ទៀងផ្ទាត់បញ្ជាក់ថាមានកំហុស) និង*
- *អភិបាលកិច្ចល្អ (តម្លាភាព និង គណនេយ្យភាព) ។*

*ប្រសិនបើច្បាប់មានតម្លាភាព និងត្រូវបានយល់ដឹងទាំងអស់គ្នា ហើយសកម្មភាពឆ្លើយតបត្រូវបានអនុវត្តភ្លាមៗនៅពេលដែលរកឃើញថារបាយការណ៍មិនត្រឹមត្រូវ ហើយកំហុសនិងផលវិបាកទាំងឡាយត្រូវបានផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់ ដូចនេះការប្រព្រឹត្តកំហុសនឹងត្រូវបានកាត់បន្ថយជាអប្បរមា ។*

## ៥.៣ ការដាក់ពិន័យ

*ការដាក់ពិន័យជាយថាហេតុ ត្រូវអនុវត្តចំពោះតែថវិកាផ្សារភ្ជាប់ស្នាដៃការងារតែប៉ុណ្ណោះ និងមិនប៉ះពាល់ដល់កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាលឡើយ ។*

***ទាក់ទងទៅនឹងការផ្ទៀងផ្ទាត់តាមក្រោមពីអ្នកវាយតម្លៃគុណភាពពីខាងក្រៅ៖*** *ការវាយតម្លៃនេះត្រូវយកចិត្តទុកដាក់ទាំងការគ្រប់គ្រងសុខាភិបាល និង ទាំងមូលដ្ឋានសុខាភិបាល ។ ភាពខុសគ្នាដោយអន្លើ ត្រូវបានគណនាដោយការប្រៀបធៀបពិន្ទុ រវាងការផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកាជាមួយនឹង ការវាយតម្លៃមុនផ្តល់ថវិកា ។* ***ក្នុងករណីនៃរបាយការណ៍មិនត្រឹមត្រូវ៖*** *ការិយាល័យស្រុកប្រតិបត្តិ មណ្ឌលសុខភាព ការិយាល័យមន្ទីរសុខាភិបាលខេត្ត និង មន្ទីរពេទ្យ ត្រូវដាក់ពិន័យដូចខាងក្រោម៖*

- *ប្រសិនបើភាពខុសគ្នានេះមានទំហំ* ***ធំជាង ១០%*** *រវាងការវាយតម្លៃផ្ទៀងផ្ទាត់ក្រោយផ្តល់ថវិកា និងការវាយតម្លៃមុនដំបូង ឬ មានការបញ្ជាក់យ៉ាងច្បាស់ថាមានចេតនា ឬ មានការកើតឡើងម្តងហើយម្តងទៀតនៃភាពខុសគ្នាដែលបានរកឃើញពីមុន និង គ្មានការពន្យល់ពីភាពខុសគ្នានេះដែលអាចជឿទុកចិត្តបាន (មធ្យមភាគនៅលើសំណាកគំរូនៃសេវាកម្ម យោងតាម ពិធីសារ)៖*

I. ***ការកើតឡើងបញ្ហាលើកដំបូង***

- ***សម្រាប់ ការិយាល័យស្រុកប្រតិបត្តិ ឬ ការិយាល័យមន្ទីរសុខាភិបាលខេត្ត៖***

(1) កាត់ទុក ៥០% នៃថវិកាដែលរកបានពីស្នាដៃការងារនៃការវាយតម្លៃមុនផ្តល់ថវិកានៅក្នុងមូលដ្ឋានសុខាភិបាលនោះសម្រាប់ត្រីមាសបន្ទាប់

(2) ថវិការកបានដែលនៅសេសសល់អាចត្រូវចំណាយសម្រាប់ជាប្រាក់រង្វាន់ស្នាដៃការងាររបស់បុគ្គលម្នាក់ៗ

(3) ការព្រមានផ្ទាល់មាត់ទៅប្រធានមន្ទីរសុខាភិបាល បន្ទាប់មកការព្រមានផ្ទាល់មាត់ដោយប្រធានមន្ទីរសុខាភិបាល ដល់អ្នកវាយតម្លៃផ្ទៀងផ្ទាត់ដោយមានការចូលរួមពីប្រធានការិយាល័យស្រុកប្រតិបត្តិ

(4) ការដាក់បញ្ចូលដោយស្វ័យប្រវត្តិទៅក្នុងជុំបន្ទាប់នៃគុណភាព នូវការផ្ទៀងផ្ទាត់ឡើងវិញ

- **សម្រាប់ មូលដ្ឋានសុខាភិបាល៖**

(1) កាត់ទុក ២០% នៃថវិការកបានសរុប ពីការទូទាត់ចំណាយបន្ទាប់

(2) ថវិការកបានដែលនៅសេសសល់អាចត្រូវចំណាយសម្រាប់ជាប្រាក់រង្វាន់ស្នាដៃការងាររបស់បុគ្គលម្នាក់ៗ

II. ការកើតឡើងបញ្ហាលើកទី២

- **សម្រាប់ការិយាល័យស្រុកប្រតិបត្តិ ឬ ការិយាល័យមន្ទីរសុខាភិបាលខេត្ត៖**

(1) កាត់ទុក ៥០% នៃថវិកាដែលរកបានពីស្នាដៃការងារនៃការវាយតម្លៃមុនផ្តល់ថវិកានៅក្នុងមូលដ្ឋានសុខាភិបាលនោះ សម្រាប់ត្រីមាសបន្ទាប់

(2) ថវិការកបានដែលនៅសេសសល់ **មិនអាចចំណាយ** សម្រាប់ជាប្រាក់រង្វាន់លើស្នាដៃការងាររបស់បុគ្គលម្នាក់ៗទេ

(3) លិខិតព្រមានជាលាយលក្ខណ៍អក្សរចំពោះប្រធានមន្ទីរសុខាភិបាល ឬប្រធានការិយាល័យស្រុកប្រតិបត្តិ

(4) ការដាក់បញ្ចូលដោយស្វ័យប្រវត្តិទៅក្នុងជុំបន្ទាប់នៃគុណភាព នូវការផ្ទៀងផ្ទាត់ឡើងវិញ និង

(5) ការដកអ្នកវាយតម្លៃគុណភាពដែលទទួលខុសត្រូវចេញពីប្រាក់រង្វាន់ស្នាដៃការងារ និងពីបញ្ជីផ្ទៀងផ្ទាត់សម្រាប់រយៈពេលមួយឆ្នាំ

- **សម្រាប់មូលដ្ឋានសុខាភិបាល៖**

(1) កាត់ទុក ៣០% នៃថវិកាដែលរកបានពីស្នាដៃការងារនៃការវាយតម្លៃមុនផ្តល់ថវិកា នៅក្នុងមូលដ្ឋានសុខាភិបាលនោះ សម្រាប់ត្រីមាសបន្ទាប់

(2) ថវិការកបានដែលនៅសេសសល់ **មិនអាចចំណាយ** សម្រាប់ជាប្រាក់រង្វាន់លើស្នាដៃការងាររបស់បុគ្គលម្នាក់ៗទេ

(3) គណៈកម្មការមូលដ្ឋានសុខាភិបាលត្រូវបានជូនព័ត៌មានជាលាយលក្ខណ៍អក្សរ

## III. ការកើតឡើងបញ្ហាលើកទី៣

- **សម្រាប់ការិយាល័យស្រុកប្រតិបត្តិ ឬ ការិយាល័យមន្ទីរសុខាភិបាលខេត្តៈ**

(1) បញ្ឈប់ការទូទាត់លើស្នាដៃការងារសម្រាប់រយៈពេល១ឆ្នាំ ពីសមាសភាគការលើកកម្ពស់គុណភាពសេវាសម្រាប់មូលដ្ឋានសុខាភិបាលនោះ (ឬរហូតដល់រកឃើញដំណោះស្រាយដោយពេញចិត្តមួយសម្រាប់នាយកដ្ឋានសេវាមន្ទីរពេទ្យនៃក្រសួងសុខាភិបាល) និង

(2) ផ្តល់កិច្ចសន្យាអភិបាលគុណភាពទៅឱ្យការិយាល័យស្រុកប្រតិបត្តិ ឬ ការិយាល័យមន្ទីរសុខាភិបាលខេត្តផ្សេងទៀត រង់ចាំរហូតដល់ដំណោះស្រាយនៃវិបត្តិត្រូវបានដោះស្រាយ ។

- **សម្រាប់មូលដ្ឋានសុខាភិបាលៈ**

(1) រហូតដល់សកម្មភាពរដ្ឋបាលត្រូវបានដោះស្រាយ

### តារាងទី ៣ ការពិន័យក្នុងករណីដែលលទ្ធផលខុសគ្នា លើសពី ១០% មិនអាចពន្យល់បានពីការផ្ទៀងផ្ទាត់ក្រោយការវាយតម្លៃ

| ការកើតឡើងនៃបញ្ហា | សម្រាប់ការិយាល័យស្រុកប្រតិបត្តិ/មន្ទីរសុខាភិបាល | | | សម្រាប់មូលដ្ឋានសុខាភិបាល | | |
|---|---|---|---|---|---|---|
| | ការព្រមាន | ការកាត់ថវិកាទុក | ថវិកានៅសល់ | ការព្រមាន | ការកាត់ថវិកាទុក | ថវិកានៅសល់ |
| លើកទី១ | ការព្រមានផ្ទាល់មាត់ | ៥០% នៃការទូទាត់ទាក់ទងនឹង | ៥០% នៃប្រាក់រង្វាន់ ឬ/និងតម្លៃ | ការព្រមានជាលាយលក្ខ | ២០% នៃការទូទាត់ទាក់ទងនឹង | ៨០% នៃប្រាក់រង្វាន់ |

| | | | | | | |
|---|---|---|---|---|---|---|
| | ដល់ក្រុមវាយតម្លៃ | ស្នាដៃការងារ | ប្រតិបត្តិ (តម្រូវឲ្យមានការអភិបាលដោយការិយាល័យស្រុកប្រតិបត្តិ និងការិយាល័យមន្ទីរសុខាភិបាលខេត្ត) | ណ៍អក្សរទៅការិយាល័យមន្ទីរសុខាភិបាលខេត្ត<br><br>ការព្រមានផ្ទាល់មាត់ពីការិយាល័យមន្ទីរសុខាភិបាលខេត្តដល់អ្នកវាយតម្លៃ | ស្នាដៃការងារ | (ឬតម្លៃប្រតិបត្តិ) |
| លើកទី២ | ការព្រមានជាលាយលក្ខណ៍អក្សរដល់ក្រុមវាយតម្លៃ | ៥០% | ៥០% នៃតម្លៃប្រតិបត្តិការប៉ុណ្ណោះ | ការព្រមានជាលាយលក្ខណ៍អក្សរទៅមន្ទីរសុខាភិបាលខេត្តនិងទៅអ្នកវាយតម្លៃ | ៣០% | ៧០% នៃតម្លៃប្រតិបត្តិការ |
| លើកទី៣ | បញ្ឈប់ការទូទាត់លើស្នាដៃការងារសម្រាប់រយៈពេល១ឆ្នាំ ឬ រហូតដល់ រកឃើញនូវដំណោះស្រាយដោយពេញចិត្តមួយ | | | | | |

# ៦. ការគ្រប់គ្រងហិរញ្ញវត្ថុ

ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ក្នុងសេចក្ដីណែនាំស្ដីអំពីការប្រើប្រាស់ថវិកាដើម្បីផ្ដល់សេវា គឺជាសេចក្ដីណែនាំបន្ថែមលើ នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោង (SOP/FMM) ។ ការត្រួតពិនិត្យទូទៅ និង និតិវិធី នៃការគ្រប់គ្រងហិរញ្ញវត្ថុ មានបរិយាយនៅផ្នែក នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោង(SOP/FMM) ចំណែកការគ្រប់គ្រងហិរញ្ញវត្ថុក្នុងសេចក្ដីណែនាំនេះបរិយាយនូវដំណើរការជាលំដាប់លំដោយ សម្រាប់ការគ្រប់គ្រងកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល (Fixed Lump-Sum Grant) និងកញ្ចប់ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ (Performance-based Grant) ។

ដំណើរការនិង ទម្រង់គណនេយ្យនានា ត្រូវបានគាក់តែងឡើង ក្នុងគោលបំណងសម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធការងារដោយដៃតែប៉ុណ្ណោះ ។ អង្គភាពនានាអាចប្រើប្រាស់ តារាងអ៊ិចសែល ដើម្បីសម្រួលដល់ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់ពួកគេ ។ ប្រសិនជាមានប្រើប្រាស់កម្មវិធីគណនេយ្យកុំព្យូទ័រព័ត៌មានខ្លះនៅក្នុងទម្រង់គណនេយ្យ និង ដំណើរការត្រូវធ្វើការកែតម្រូវ ហើយត្រូវរៀបចំបង្កើតប្លង់គណនេយ្យផងដែរ ។

## ៦.១ រចនាសម្ព័ន្ធនៃការគ្រប់គ្រងហិរញ្ញវត្ថុ

ថ្នាក់គ្រប់គ្រង និង បុគ្គលិក នៃមន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មន្ទីរពេទ្យខេត្ត មន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព ដែលទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុមានបង្ហាញនៅក្នុងគំនូសបង្ហាញដូចខាងក្រោម៖

រូបភាពទី២៖ រចនាសម្ព័ន្ធគ្រប់គ្រង ហិរញ្ញវត្ថុ សម្រាប់ មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មន្ទីរពេទ្យខេត្ត និង មន្ទីរពេទ្យបង្អែក



តារាងទី៥៖ សង្ខេបអំពីតួនាទី ភារៈកិច្ច ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ថ្នាក់ មន្ទីរសុខាភិបាលខេត្ត មន្ទីរពេទ្យខេត្ត ស្រុកប្រតិបត្តិ និង មន្ទីរពេទ្យបង្អែក

| តួនាទី | ការទទួលខុសត្រូវចម្បង |
|---|---|
| ប្រធានអង្គភាព | - ទទួលខុសត្រូវលើរាល់ប្រតិបត្តិការណ៍ហិរញ្ញវត្ថុ<br>- ធ្វើការអនុម័តរាល់ការចំណាយ និង ការទូទាត់<br>- ធានាថា ការចំណាយទាំងអស់អាចទទួលយកបាន និង អនុលោមតាមគោលការណ៍ និង និតិវិធីហិរញ្ញវត្ថុ |
| ប្រធានគណនេយ្យ | - ត្រួតពិនិត្យ នូវភាពត្រឹមត្រូវ និង ភាពពេញលេញ លើរាល់ព័ត៌មាន នៃកិច្ចការដែលបានអនុវត្តដោយ គណនេយ្យករ និង បេឡាករ<br>- តាមដានថវិកា និង ផែនការការងាររបស់អង្គភាព<br>- ពិនិត្យឡើងវិញអំពីសុពលភាព និងភាពត្រឹមត្រូវរបស់ឯកសារគាំទ្រនានា និង ការចំណាយទាំងឡាយ ថាវាស្របច្បាប់ និង អនុលោមតាមផែនការការងារ របស់អង្គភាព<br>- ពិនិត្យ សំណើសុំទិញ និងធ្វើការប្រមាណតម្លៃឯកតាឲ្យបានសមស្រប<br>- ពិនិត្យ ឯកសារដែលទាក់ទងនឹងការទិញ |
| គណនេយ្យករ | - រៀបចំ ប័ណ្ណចំណាយ ប័ណ្ណចំណូល<br>- គ្រប់គ្រងសៀវភៅធនាគារ<br>- រៀបចំរបាយការណ៍សម្របសម្រួលធនាគារ<br>- គ្រប់គ្រងបញ្ជីកត់ត្រា បុរេប្រទាន<br>- ធ្វើសេចក្តីព្រាងរបាយការណ៍ហិរញ្ញវត្ថុ<br>- ទំនាក់ទំនងជាមួយ ធនាគារ ដើម្បី ដាក់ និងទទួល ឯកសារ (ប្រកាស ឥណទាន របាយការណ៍ធនាគារ...) |

| | |
|---|---|
| បេឡាករ | - រៀបចំប័ណ្ណចំណាយ ដែលប្រើប្រាស់ សាច់ប្រាក់រជ្ជទេយ្យ<br>- គ្រប់គ្រង សាច់ប្រាក់រជ្ជទេយ្យ និង បញ្ជីកត់ត្រា<br>- ធ្វើការរាប់សាច់ប្រាក់<br>- ទំនាក់ទំនងជួបជាមួយ ធនាគារ ដើម្បី ដាក់ និងទទួល ឯកសារ (ប្រកាសឥណទាន របាយការណ៍ធនាគារ...) |

*រូបភាពទី៣៖ រចនាសម្ព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់មណ្ឌលសុខភាព*




*តារាងទី៦៖ សង្ខេបអំពីការទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់មណ្ឌលសុខភាព*

| តួនាទី | ការទទួលខុសត្រូវចំបង |
|---|---|
| ប្រធាន | - ទទួលខុសត្រូវលើរាល់ប្រតិបត្តិការណ៍ហិរញ្ញវត្ថុ<br>- ធ្វើការអនុម័ត រាល់ការចំណាយ និង ការទូទាត់<br>- ធានាថា ការចំណាយទាំងអស់អាចទទួលយកបាន និង អនុលោមតាម គោលការណ៍ និង និតិវិធីហិរញ្ញវត្ថុ |
| គណនេយ្យករ | - ត្រួតពិនិត្យ នូវភាពត្រឹមត្រូវ និង ភាពពេញលេញ លើរាល់ព័ត៌មាន នៃកិច្ចការដែលបានអនុវត្តដោយ គណនេយ្យករ និង បេឡាករ<br>- តាមដានថវិកា និង ផែនការ ការងាររបស់អង្គភាព<br>- ពិនិត្យឡើងវិញអំពីសុពលភាព និងភាពត្រឹមត្រូវរបស់ឯកសារគាំទ្រនានា និង ការចំណាយទាំងឡាយ ថាវាមានភាពស្របច្បាប់ និង អនុលោមតាមផែនការការងារ របស់អង្គភាព<br>- គ្រប់គ្រងបញ្ជីកត់ត្រាបុរេប្រទាន |

| | |
|---|---|
| | - ពិនិត្យ សំណើសុំទិញ និងធ្វើការប្រមាណតម្លៃឯកតាឲ្យបានសមស្រប<br>- ពិនិត្យឯកសារនានាដែលទាក់ទងនឹងការទិញ |
| បេឡាករ | - រៀបចំវិក្កយបត្រចំណាយ ដែលប្រើប្រាស់ សាច់ប្រាក់រដ្ឋទេយ្យ<br>- គ្រប់គ្រង សាច់ប្រាក់រដ្ឋទេយ្យ និង បញ្ជីរកត់ត្រា<br>- ធ្វើការរាប់សាច់ប្រាក់<br>- រៀបចំរបាយការណ៍សម្របសម្រួលពីធនាគារ<br>- គ្រប់គ្រងសៀវភៅធនាគារ<br>- ទំនាក់ទំនងជួបជាមួយ ធនាគារ ដើម្បី ដាក់ និងទទួល ឯកសារ (ឯកសារប្រកាសឥណទាន របាយការណ៍ធនាគារ...) |

ករណីដែល មណ្ឌលសុខភាព មិនមានបុគ្គលិកជាអ្នកជំនាញគណនេយ្យ ឬបេឡាករទេ ប្រធានមណ្ឌលសុខភាព អាចចាត់តាំងអនុប្រធាន ឬ បុគ្គលិកផ្សេងទៀត ឲ្យទទួលខុសត្រូវអនុវត្តមុខងារ ជាគណនេយ្យករ ឬ បេឡាករ ថែមពីលើកិច្ចការធម្មតារបស់ពួកគាត់នៅមណ្ឌលសុខភាព ។

## ៦.២ រំហូរថវិកា

នាពេលបច្ចុប្បន្ន រំហូរថវិកាមានពីរប្រភេទ៖

I. កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល ផ្តល់ដោយរាជរដ្ឋាភិបាលសម្រាប់មូលដ្ឋានសុខាភិបាល ដែលអាចប្រើប្រាស់សម្រាប់ ចំណាយប្រតិបត្តិការតែប៉ុណ្ណោះ ដោយមិនអាចប្រើប្រាស់ជាប្រាក់លើកទឹកចិត្តដល់បុគ្គលិកឡើយ

II. ថវិកាផ្សារភ្ជាប់ស្នាដៃការងារ ផ្តល់ដោយ រាជរដ្ឋាភិបាលកម្ពុជា សមាគមន៍អភិវឌ្ឍន៍អន្តរជាតិ (IDA) និង មូលនិធិពហុភាគី (MDTF) សម្រាប់មូលដ្ឋានសុខាភិបាល ការិយាល័យស្រុកប្រតិបត្តិ ការិយាល័យមន្ទីរសុខាភិបាលខេត្ត ដែលអាចប្រើប្រាស់បានទាំងពីរប្រការ គឺ ចំណាយប្រតិបត្តិការ និង ប្រាក់លើកទឹកចិត្តដល់បុគ្គលិក ។

*រូបភាពទី៤៖ គំនូសតាងលំហូរថវិកា នៃកញ្ចប់ថវិកាទាំងពីរ*




*ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល ត្រូវផ្ទេរពីរតនាគារខេត្ត ទៅគណនីជាប្រាក់រៀលរបស់មូលដ្ឋានសុខាភិបាលតាមត្រីមាស ។ ភាគីផ្ទេរសិទ្ធិ ចេញបញ្ជារចំណាយប្រចាំត្រីមាស នូវចំនួនទឹកប្រាក់មិនប្រែប្រួល ដែលបានបែងចែកសម្រាប់មូលដ្ឋានសុខាភិបាលនីមួយៗ និងផ្ញើរជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ដែលមានតួនាទីត្រួតពិនិត្យ និងធ្វើសេចក្តីសម្រេច ។ បន្ទាប់មក មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត បញ្ជូនបញ្ជារចំណាយ ទៅរតនាគារខេត្ត ដើម្បីពិនិត្យ សម្រេច និង ទម្ងាក់ថវិកា ក្នុងតួនាទីជា គណនេយ្យករសាធារណៈ ។ មិនតម្រូវឱ្យមានឯកសារផ្សេងទៀតភ្ជាប់នឹងបញ្ជារចំណាយឡើយ ។*

*ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ ត្រូវបានផ្ទេរពីគណនីថវិកាបដិភាគ នៅធនាគារជាតិកម្ពុជា និងគណនីថវិកា* Designated Account (*សមាគមអភិវឌ្ឍន៍អន្តរជាតិ និង មូលនិធិពហុភាគី*) *នៅធនាគារជាតិកម្ពុជា ទៅកាន់គណនីជាប្រាក់រៀលនៅធនាគាររបស់មូលដ្ឋានសុខាភិបាល ប្រចាំត្រីមាស ផ្អែកតាមលទ្ធ*

*ផលនៃការវាយតម្លៃស្នាដៃការងារ ។ បន្ទាប់ពីការវាយតម្លៃស្នាដៃការងារ ដែលលទ្ធផលរបស់គេត្រូវធ្វើរួចរាល់ នារៀងរាល់សប្តាហ៍ទីបី នៃខែបន្ទាប់ពីបញ្ចប់ត្រីមាស ក្រុមការងារបង្កើនគុណភាព/ការិយាល័យធានាគុណភាព នឹងធ្វើការគណនាចំនួនទឹកប្រាក់នៃថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ (បញ្ជាក់ច្បាស់ពីចំនួន សម្រាប់រង្វាន់ស្នាដៃការងារ និង ចំនួនសម្រាប់ចំណាយប្រតិបត្តិការ អាស្រ័យលើលទ្ធផល នៃការវាយតម្លៃ ex-ante assessment និង ការផ្ទៀងផ្ទាត់ ex-post verfication ) សម្រាប់អង្គភាពនីមួយៗ រួមមាន មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ការិយាល័យស្រុកប្រតិបត្តិ មន្ទីរពេទ្យខេត្ត មន្ទីរសុខាភិបាលខេត្ត ហើយដាក់ជូន នាយកគម្រោង សុំសេចក្តីសម្រេច ។*

*ថវិកាដែលនៅសល់ ទាំងថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល និង ថវិកាផ្សារភ្ជាប់ស្នាដៃការងារ នាចុងត្រីមាស និង ចុងឆ្នាំ នឹងត្រូវបានអនុញ្ញាតិឲ្យបូកយោង ទៅត្រីមាសបន្ទាប់ និង ឆ្នាំបន្ទាប់ ។*

# ៦.៣ គណនេយ្យ និង ការថែរក្សាកំណត់ត្រាគណនេយ្យ

## ៦.៣.១ ប្រាក់រង្វនេយ្យ

*ពិដានទឹកប្រាក់រជ្ជទេយ្យនិងការគ្រប់គ្រងប្រាក់រជ្ជទេយ្យ*

*ប្រាក់រជ្ជទេយ្យ ត្រូវបានអនុញ្ញាតិឲ្យចំណាយលើឯកតាតូចតាច ដូចជា សម្ភារៈការិយាល័យ ជួសជុលតូច ចំណាយប្រាក់បេសសកម្ម ប្រាក់ធ្វើដំណើរ ចំណាយបណ្តុះបណ្តាល (ប្រសិនបើមាន) និង ការចំណាយសម្រាប់ការប្រជុំ ។ល។ (សូមអានផ្នែកទី ៥) ។ ពិដានទឹកប្រាក់រជ្ជទេយ្យមានចំនួន ៤,០០០,០០០ រៀល ។ ដើម្បីជៀសវាងការអាក់ខាននៃប្រតិបត្តិការ ចំនួនអប្បបរមានៃប្រាក់រជ្ជទេយ្យ ត្រូវកំណត់តាមអង្គភាពនីមួយៗ ដោយផ្អែកលើទំហំនៃការចំណាយពីកញ្ចប់ប្រាក់រជ្ជទេយ្យ និង តម្រូវការជាក់ស្តែង ។*

*ប្រាក់រជ្ជទេយ្យ ត្រូវគ្រប់គ្រងដោយបេឡាករ ដែលជាអ្នករក្សាទុកសាច់ប្រាក់ក្នុងទូរសុវត្ថិភាព ។ ទូរសុវត្ថិភាពត្រូវមានសោរ និងលេខសម្ងាត់ ។ លេខសម្ងាត់ត្រូវរក្សាទុកដោយបេឡាករ និង សោរត្រូវរក្សាទុកដោយគណនេយ្យករ នៃមណ្ឌលសុខភាព ឬ ប្រធានគណនេយ្យ សម្រាប់ថ្នាក់ មន្ទីរសុខាភិបាលខេត្ត មន្ទីរពេទ្យខេត្ត ការិយាល័យស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក ។*

### ៦.៣.១.១ ការបំពេញឡើងវិញនៃកញ្ចប់ប្រាក់រង្វេទយ្យ

*តារាងទី៧៖ ការបំពេញឡើងវិញនៃប្រាក់រដ្ឋទេយ្យ*

| និតិវិធី | មន្ទីរសុខាភិបាលខេត្ត / មន្ទីរពេទ្យខេត្ត / ការិយាល័យស្រុកប្រតិបត្តិ / មន្ទីរពេទ្យបង្អែក<br>- អនុវត្តដោយ: | មណ្ឌលសុខភាព<br>- អនុវត្តដោយ: |
|---|---|---|
| 1. ក្នុងកូឡោនចំណាយក្នុងសៀវភៅកត់ត្រាប្រាក់រដ្ឋទេយ្យ ត្រូវបូកសរុប តាមប្រភេទចំណាយនីមួយៗ ។ នៅពេលដែលត្រូវការបំពេញទឹកប្រាក់ឡើងវិញ សំណើសុំបំពេញទឹកប្រាក់ (ឧបសម្ព័ន្ធទី FM-10) ត្រូវបានរៀបចំ ចុះហត្ថលេខា និងភ្ជាប់ជាមួយនូវច្បាប់ចម្លងនៃសៀវភៅកត់ត្រាប្រាក់រដ្ឋទេយ្យ ដែលមានសរុបចំណាយបានទូទាត់នៅក្នុងកំឡុងពេលនោះ ។ | បេឡាករ | បេឡាករ |
| 2. ពិនិត្យឡើងវិញនូវព័ត៌មាន ក្នុងសំណើបំពេញឡើងវិញកញ្ចប់ប្រាក់រដ្ឋទេយ្យ និង ច្បាប់ចំលងនៃសៀវភៅកត់ត្រាប្រាក់រដ្ឋទេយ្យ | ប្រធានគណនេយ្យ | គណនេយ្យករ |
| 3. ប្រសិនសំណើសុំត្រឹមត្រូវ សក្ខីប័ត្រដកប្រាក់ (DV) និង មូលប្បទានប័ត្រ ត្រូវរៀបចំ និង ដំណើរការសម្រាប់ទូទាត់ ។ អានលម្អិត នៅផ្នែក៧.៣.៤ | | |
| 4. កត់ត្រាលម្អិតអំពីការទូទាត់ រួមមានមុខចំណាយផ្សេងៗ ក្នុងសៀវភៅធនាគារ | គណនេយ្យករ | បេឡាករ |

| | | |
|---|---|---|
| 5. បន្ទាប់ពីទទួលសាច់ប្រាក់ពីមូលប្បទានប័ត្រ សាច់ប្រាក់ត្រូវទុកក្នុងទូរសុវត្ថិភាព និងកត់ត្រាក្នុងសៀវភៅប្រាក់រដ្ឋទេយ្យ ក្នុងកូឡោនទទួលប្រាក់ ។ | បេឡាករ | បេឡាករ |

### ៦.៣.១.២ ការរាប់សាច់ប្រាក់ជាទៀងទាត់

បេឡាករត្រូវរាប់សាច់ប្រាក់ជាក់ស្តែងនៅក្នុងដៃ ដោយមានការសង្កេតពីអ្នក (គណនេយ្យករ ប្រធានគណនេយ្យ) មុនពេលបិទបញ្ជីនាថ្ងៃចុងក្រោយនៃខែ បេឡាករនឹងធ្វើការរាប់ក្រដាសប្រាក់នៅចំពោះមុខអ្នកសង្កេតមើលដែលបានជ្រើសរើស ( គណនេយ្យករ ឬ ប្រធានគណនេយ្យ ) ។ លទ្ធផលនៃការរាប់នេះនឹងកត់ត្រាក្នុងតារាងរាប់សាច់ប្រាក់ (ឧបសម្ព័ន្ធ FM8) ។ ក្រោយពេលរាប់ចប់ ត្រូវធ្វើការផ្ទៀងផ្ទាត់រវាងចំនួនទឹកប្រាក់ក្នុងបញ្ជីកត់ត្រា និង ចំនួនពីលទ្ធផលនៃការរាប់ ។ បើមានភាពខុសគ្នាត្រូវកត់ត្រាក្នុងតារាងរាប់សាច់ប្រាក់ ។

តារាងរាប់សាច់ប្រាក់ត្រូវទទួលការសម្រេចពីគណនេយ្យករ និង ប្រធានអង្គភាព សម្រាប់មណ្ឌលសុខភាព និងដោយប្រធានគណនេយ្យ និង ប្រធានអង្គភាព សម្រាប់ថ្នាក់មន្ទីរសុខាភិបាលខេត្ត មន្ទីរពេទ្យខេត្ត ការិយាល័យស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក ។

### ៦.៣.១.៣ ការរាប់សាច់ប្រាក់ដោយចៃដន្យដែលមិនជូនដំណឹងមុន

កញ្ចប់ទឹកប្រាក់រដ្ឋទេយ្យ នឹងត្រូវរាប់ដោយចៃដន្យនាពេលណាមួយដោយថ្នាក់គ្រប់គ្រងអង្គភាព ឬ ដោយសវនករផ្ទៃក្នុង ឬ មកពីខាងក្រៅ ។ ប្រសិនជាមានការរាប់សាច់ប្រាក់ដោយចៃដន្យ ការនេះត្រូវកត់ត្រាក្នុងតារាងរាប់សាច់ប្រាក់ ហើយត្រូវធ្វើការផ្ទៀងផ្ទាត់សមតុល្យនៅក្នុងបញ្ជីកត់ត្រា ។

### ៦.៣.២ ធនាគារ

### ៦.៣.២.១ គណនីធនាគារ

មន្ទីរសុខាភិបាល និងការិយាល័យស្រុកប្រតិបត្តិនីមួយៗ មានគណនីចរន្តជាប្រាក់រៀលនៅតាមធនាគារពាណិជ្ជដែលជ្រើសរើសដោយក្រសួងសុខាភិបាល សម្រាប់ទទួលថវិកាផ្សារភ្ជាប់ស្នាដៃការងារ។

មន្ទីរពេទ្យខេត្ត មន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព នីមួយៗ មានគណនីចរន្តជាប្រាក់រៀលមួយ នៅធនាគារពាណិជ្ជ សម្រាប់ទទួលថវិកាទាំងពីរ គឺ កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល និង ថវិកាផ្សារភ្ជាប់ស្នាដៃការងារ ។ ដោយសារតែភាព

សាមញ្ញនៃការទម្លាក់ថវិកាប្រចាំត្រីមាសនៃថវិកាទាំងពីរនេះ គណនីធនាគារតែមួយ គឺគ្រប់គ្រាន់សម្រាប់ចាត់ចែងថវិកាទាំងពីរនេះ ។

### ៦.៣.២.២ ហត្ថលេខាដែលមានសិទ្ធ

ព័ត៌មានលម្អិតអំពីគណនីចរន្ត (គណនីមូលប្បទានប័ត្រ) រួមមានគំរូហត្ថលេខា និង ការផ្លាស់ប្តូរនានាត្រូវផ្តល់ជូន នាយកដ្ឋានថវិកានិងហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល ។

អ្នកចុះហត្ថលេខាដែលមានសិទ្ធិជាផ្លូវការសម្រាប់ការដកប្រាក់តាមមូលប្បទានប័ត្រ និងឯកសារសំខាន់ៗដទៃទៀត ត្រូវយកពីររូបក្នុងចំណោមបុគ្គលដូចខាងក្រោម៖

*ហត្ថលេខាមានសិទ្ធិជាផ្លូវការ*

*តារាងទី៨៖ ហត្ថលេខាមានសិទ្ធិជាផ្លូវការ*

| មន្ទីរសុខាភិបាល មន្ទីរពេទ្យខេត្ត ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក | មណ្ឌលសុខភាព |
|---|---|
| • ប្រធាន | • ប្រធាន |
| • អនុប្រធាន | • អនុប្រធាន |
| • ប្រធានគណនេយ្យ | • គណនេយ្យករ ឬបុគ្គលិកមណ្ឌលសុខភាពដែលបានទទួលបន្ទុកជាគណនេយ្យករ |

### ៦.៣.២.៣ អ្នកគ្រប់គ្រងមូលប្បទានប័ត្រ និង សេចក្តីណែនាំសម្រាប់រៀបចំមូលប្បទានប័ត្រ

- សៀវភៅមូលប្បទានប័ត្រដែលមិនទាន់បំពេញ ត្រូវរក្សាដោយបេឡាករ ដោយទុកក្នុងប្រអប់សុវត្ថិភាពដែលចាក់សោរ យកចេញតែពេលប្រើប្រាស់ ។
- មូលប្បទានប័ត្រត្រូវរៀបចំសរសេរតែចំនួនប្រាក់ដែលត្រូវចំណាយ ។
- ចំនួនទឹកប្រាក់ត្រូវសរសេរជាអក្សរ និង ជាលេខ ។
- សញ្ញាប្រភេទប្រាក់ ត្រូវសរសេរក្នុងទីតាំងត្រឹមត្រូវ ដែលនៅខាងឆ្វេង នៃខ្ទង់លេខដែលច្រើនជាងគេ ។

- មូលប្បទានប័ត្រដែលខូច ត្រូវគូសសញ្ញាយ៉ាងច្បាស់ ថាលុបចោល លើ ហត្ថលេខា និង ចំនួនទឹកប្រាក់ ។ សន្លឹកនេះត្រូវភ្ជាប់នឹងសៀវភៅមូលប្បទានប័ត្រ និងរក្សាទុក ។
- មូលប្បទានប័ត្រមិនអាចដកប្រាក់ដោយមិនមានឈ្មោះអ្នកទទួលឡើយ ។ មូលប្បទានប័ត្រត្រូវមានឈ្មោះអ្នកទទួលប្រាក់ ដែលជាអ្នកផ្គត់ផ្គង់ ឬ អ្នកផ្តល់សេវាជំនួយបច្ចេកទេស ។
- មិនត្រូវមានការចុះហត្ថលេខាលើមូលប្បទានប័ត្រទុកជាមុនឡើយ ។

### ៦.៣.២.៤ ការផ្ទៀងផ្ទាត់នឹងធនាគារ

ក្នុងកំឡុងពេលសប្តាហ៍ទីមួយ នៃខែបន្ទាប់ បេឡាករ ឬ គណនេយ្យករ ទទួលរបាយការណ៍ធនាគារ ។ ជំហាននៃការផ្ទៀងផ្ទាត់នឹងធនាគារត្រូវធ្វើដូចតទៅៈ

*តារាងទី៩ៈ ជំហានសម្រាប់រៀបចំផ្ទៀងផ្ទាត់នឹងធនាគារ*

| និតិវិធី | មន្ទីរសុខាភិបាលខេត្ត ពេទ្យខេត្ត ស្រុកប្រតិបត្តិ ពេទ្យអង្កែក<br>- អនុវត្តដោយ: | មណ្ឌលសុខភាព<br>- អនុវត្តដោយ: |
|---|---|---|
| 1. ពិនិត្យមើលព័ត៌មានក្នុងរបាយការណ៍ធនាគារ ដើម្បីរកមើលមូលប្បទានប័ត្រដែលមិនបានបង្ហាញ ប្រតិបត្តិការដាក់ប្រាក់បញ្ចូល និង ករណីផ្សេងៗទៀត និង បច្ចុប្បន្នភាព នៃសៀវភៅធនាគារ | គណនេយ្យករ | បេឡាករ |
| 2. រៀបចំឯកសារផ្ទៀងផ្ទាត់ប្រចាំខែ (ឧបសម្ព័ន្ធ FM ៦) | គណនេយ្យករ | បេឡាករ |
| 3. ពិនិត្យឡើងវិញ នូវការផ្ទៀងផ្ទាត់ប្រចាំខែ និង របាយការណ៍ធនាគារ | ប្រធានគណនេយ្យ | គណនេយ្យករ |

| | | |
|---|---|---|
| 4. ធ្វើសេចក្ដីសម្រេចលើឯកសារផ្ទៀងផ្ទាត់នឹងធនាគារ | ប្រធានអង្គភាព | ប្រធានមណ្ឌលសុខភាព |
| 5. រក្សាឯកសារ របាយការណ៍ធនាគារ និង អនុម័តការផ្ទៀងផ្ទាត់នឹងធនាគារ នៅក្នុងសំណុំឯកសារផ្ទៀងផ្ទាត់នឹងធនាគារ | គណនេយ្យករ | បេឡាករ |

## ៦.៣.៣ គណនេយ្យសម្រាប់ចំណូល

គណនេយ្យផ្លូវការសម្រាប់ចំណូល

តារាងទី១០៖ ប័ណ្ណចំណូលជាផ្លូវការ

| និតិវិធី | មន្ទីរសុខាភិបាលខេត្ត, ពេទ្យខេត្ត, ស្រុកប្រតិបត្តិ, ពេទ្យអង្កែក<br>- អនុវត្តដោយ: | មណ្ឌលសុខភាព<br>- អនុវត្តដោយ: |
|---|---|---|
| 6. ប្រកាសឥណទាននឹងត្រូវបានទទួលនៅពេលដែលថវិកាបានបញ្ជូនពីក្រសួងសុខាភិបាល ឬ រតនាគារខេត្ត។ សម្រាប់ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ ក្រសួងសុខាភិបាលត្រូវបញ្ជាក់ឲ្យច្បាស់ពីចំនួនទឹកប្រាក់អតិបរមាដែលត្រូវផ្តល់ជារង្វាន់ស្នាដៃការងារ ។ | គណនេយ្យករ ឬ បេឡាករ | គណនេយ្យករ ឬ បេឡាករ |
| 7. ផ្អែកលើប្រកាសឥណទាន ត្រូវរៀបចំ ប័ណ្ណចំណូល (ឧបសម្ព័ន្ធ ១) ដែលមានការបរិយាយច្បាស់លាស់ និង ចំនួនថវិកាដែលបានទទួល | គណនេយ្យករ | បេឡាករ |

| | | |
|---|---|---|
| 8. ពិនិត្យឡើងវិញនូវព័ត៌មានក្នុង ប័ណ្ណទទួលប្រាក់ និង ក្នុងប្រកាសឥណទានធនាគារ ដើម្បីធានាថា ព័ត៌មានពេញលេញ និង ត្រឹមត្រូវ | ប្រធានគណនេយ្យ | គណនេយ្យករ |
| 9. ផ្តល់សេចក្តីសម្រេចលើប័ណ្ណចំណូល | ប្រធានអង្គភាព | ប្រធានមណ្ឌលសុខភាព |
| 10. ក្រោយពីសម្រេច កត់ត្រាលម្អិតនូវប្រតិបត្តិការគណនេយ្យក្នុងសៀវភៅធនាគារ (ឧបសម្ព័ន្ធទី ៥) ដើម្បីគ្រប់គ្រងសមតុល្យសាច់ប្រាក់ក្នុងធនាគារ និង រៀបចំប្រភេទចំណូល (ឧបសម្ព័ន្ធ ១៩) ។ | គណនេយ្យករ | បេឡាករ |
| 11. រក្សាទុក ប័ណ្ណចំណូល ជាមួយនឹងប្រកាសឥណទានធនាគារ ក្នុងសំណុំឯកសារធនាគារ ដោយរៀបតាមលំដាប់ប្រចាំខែ ។ | គណនេយ្យករ | បេឡាករ |

### ៦.៣.៤ គណនេយ្យសម្រាប់ការទូទាត់

ការចំណាយទាំងអស់ ត្រូវគោរពតាម ចំនួនថវិកាដែលបានសម្រេច និងតារាងនៃសិទ្ធិចំណាយតាមលំដាប់ថ្នាក់នីមួយៗ ។ ប្រភេទនៃការចំណាយដែលមានសិទ្ធិ សម្រាប់កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល និង ថវិកាផ្សារភ្ជាប់នឹងស្នាដៃការងារ មានបរិយាយនៅឧបសម្ព័ន្ធទី ៥ នៃសេចក្តីណែនាំនេះ ។

ជាការល្អគួរធ្វើការទូទាត់តាមរយៈមូលប្បទានប័ត្រ ឬក៏ផ្ទេរតាមធនាគារ លើកលែងតែចំនួនតិចតួច ។ ការទូទាត់ ពីកញ្ចប់ប្រាក់រដ្ឋទេយ្យ គឺសម្រាប់តែការចំណាយ ឬក៏បុរេប្រទានដែលមានចំនួនតិចជាង ២,០០០,០០០ រៀល សម្រាប់មួយប្រតិបត្តិការ ។

ឯកសារសម្រាប់គាំទ្រការទូទាត់មានភាពខុសគ្នាពីមួយទៅមួយ ។ ខាងក្រោមនេះជាការណែនាំទូទៅ លើប្រភេទឯកសារសម្រាប់ការទូទាត់៖

*តារាងទី១១៖ ប្រភេទឯកសារសម្រាប់ការទូទាត់*

| ប្រភេទទូទាត់ | ឯកសារគាំទ្រ |
|---|---|
| ការបំពេញវិញនូវកញ្ចប់ប្រាក់រជ្ជទេយ្យ | • សំណើសុំបំពេញកញ្ចប់ប្រាក់រជ្ជទេយ្យ |
| បុរេប្រទាន | • សំណើសុំបុរេប្រទានដែលបានអនុម័ត |
| ទូទាត់ការចំណាយ | • សំណើរសុំទិញដែលបានអនុម័ត (ប្រសិនជាត្រូវការ)<br>• វិក្កយបត្រច្បាប់ដើមពីអ្នកផ្គត់ផ្គង់ ដែលមានព័ត៌មានលម្អិតពីទីកន្លែងអាជីវកម្ម និងចុះហត្ថលេខាដោយអ្នកទទួលខុសត្រូវ<br>• ឯកសារប្រៀបធៀបតម្លៃដែលបានអនុម័ត និង ភ្ជាប់នូវឯកសារសម្រង់តម្លៃទាំងអស់ (ប្រសិនបើមាន)<br>• តារាងពេលវេលាធ្វើការងាររបស់អ្នកផ្តល់សេវាជំនួយបច្ចេកទេស (ប្រសិនបើមាន) |
| ការជម្រះបញ្ជីបុរេប្រទានសម្រាប់ ការប្រជុំ / សិក្ខាសាលា | • របាយការណ៍ចំណាយដែលបានអនុម័ត<br>• តារាងប្រាក់ឧបត្ថម្ភដែលមានចុះហត្ថលេខាដោយបុគ្គលម្នាក់ៗ<br>• វិក្កយបត្រចំណាយច្បាប់ដើម<br>• បញ្ជីឈ្មោះអ្នកចូលរួម<br>• របៀបវារៈ (បើមាន)<br>• របាយការណ៍ដោយមានរូបភាពនៃព្រឹត្តិការណ៍<br>• ទំព័រមុខឯកសារ ដែលមានចុះចំនួនទំព័រ ដើម្បីបញ្ជាក់អំពីចំនួនដែលបានថតចម្លង ។ |

ការចំណាយទាំងអស់ត្រូវធ្វើជាប្រាក់រៀល ។ អត្រាប្តូរប្រាក់ជាផ្លូវការ នៅថ្ងៃប្រតិបត្តិការចំណាយ នឹងត្រូវប្រើសម្រាប់ការគណនាជាប្រាក់រៀល ពីប្រភេទប្រាក់ផ្សេងៗ ។

### ៦.៣.៤.១ ការទូទាត់ពីប្រាក់រដ្ឋទេយ្យ

| និតិវិធី | មន្ទីរសុខាភិបាលខេត្ត ពេទ្យខេត្ត, ស្រុក ប្រតិបត្តិ ពេទ្យអង្អែក - អនុវត្តដោយ: | មណ្ឌលសុខភាព - អនុវត្តដោយ: |
|---|---|---|
| 6. ដាក់ជូននូវឯកសារពាក់ព័ន្ធទាំងឡាយដើម្បីគាំទ្រ សំណើរសុំ | អ្នកស្នើសុំ | អ្នកស្នើសុំ |
| 7. ផ្អែកលើឯកសារ រៀបចំវិក្កយបត្របង់ប្រាក់ (ឧបសម្ព័ន្ធទី ៣) ដែលមានបរិយាយលម្អិត និង ចំនួនប្រាក់ដែលត្រូវទូទាត់ | បេឡាករ | បេឡាករ |
| 8. ពិនិត្យឡើងវិញនូវឯកសារ វិក្កយបត្របង់ប្រាក់ និងឯកសារគាំទ្រ ដើម្បីធានាថា ព័ត៌មាន មាន ភាពត្រឹមត្រូវគ្រប់គ្រាន់ និងពេញលេញ ហើយ ការទូទាត់មានភាពស្របច្បាប់ និង ត្រូវតាម ផែនការ | ប្រធានគណនេយ្យ | គណនេយ្យករ |
| 9. ធ្វើការសម្រេចលើវិក្កយបត្របង់ប្រាក់ | ប្រធានអង្គភាព | ប្រធានមណ្ឌលសុខ ភាព |
| 10. ក្រោយពីការសម្រេច បញ្ចេញសាច់ប្រាក់ ឲ្យអ្នក ទទួលប្រាក់ចុះហត្ថលេខាលើវិក្កយបត្របង់ប្រា ក់ៗ បោះត្រា "PAID" លើវិក្កយបត្រច្បាប់ដើម និង ឯកសារសំខាន់ដទៃទៀត ដើម្បីប្រើប្រាស់ក្នុងការ ដាក់យកប្រាក់ទូទាត់បង្គ្រប់វិញ ។ | បេឡាករ | បេឡាករ |
| 11. ក្រោយការទូទាត់ កត់ត្រាប្រតិបត្តិការចំណាយ ក្នុងបញ្ជីរកត់ត្រារដ្ឋទេយ្យ (ឧបសម្ព័ន្ធទី ៧) ដើម្បី គ្រប់គ្រងសមតុល្យនៃទឹកប្រាក់ក្នុងដៃ នឹងរៀបចំ ការចំណាយតាមចំណាត់ថ្នាក់ ។ | បេឡាករ | បេឡាករ |

| | | |
|---|---|---|
| 12. រក្សាទុកវិក្កយបត្របង់ប្រាក់ ជាមួយគ្នានឹងឯកសារគាំទ្រនានា ក្នុងសំណុំឯកសារប្រាក់រដ្ឋទេយ្យ ដោយរៀបតាមលេខរៀង និងតាមខែ | បេឡាករ | បេឡាករ |

## ៦.៣.៤.២ ការទូទាត់តាមធនាគារ

ការទូទាត់តាមធនាគារអាចធ្វើតាមមូលប្បទានប័ត្រ ឬ ក៏ការផ្ទេរតាមធនាគារ ។ ការទូទាត់ប្រាក់លើកទឹកចិត្តសម្រាប់ស្នាដៃការងារបុគ្គលិកនឹងផ្ទេរទៅកាន់គណនីរបស់បុគ្គលិកម្នាក់ៗ ។

| និតិវិធី | មន្ទីរសុខាភិបាលខេត្ត ពេទ្យខេត្ត ស្រុកប្រតិបត្តិ, ពេទ្យអង្គែក<br>- អនុវត្តដោយ | មណ្ឌលសុខភាព<br>- អនុវត្តដោយ |
|---|---|---|
| 13. ដាក់នូវឯកសារទាក់ទងទាំងឡាយដែលគាំទ្រដល់ការស្នើសុំ | អ្នកស្នើសុំ | អ្នកស្នើសុំ |
| 14. ផ្អែកលើឯកសារ រៀបចំប័ណ្ណបញ្ចេញប្រាក់ (ឧបសម្ព័ន្ធទី ២) ដែលមានបរិយាយច្បាស់ និងចំនួនទឹកប្រាក់ដែលត្រូវទូទាត់ ។ រៀបចំមូលប្បទានប័ត្រដាក់ឈ្មោះ ក្រុមហ៊ុន ឬអ្នកទទួលប្រាក់ ។ បើការទូទាត់តាមរយៈផ្ទេរដោយធនាគារ ត្រូវរៀបចំ លិខិតធ្វើការផ្ទេរ ។ | គណនេយ្យករ | បេឡាករ |
| 15. ពិនិត្យព័ត៌មានលើប័ណ្ណបញ្ចេញប្រាក់ មូលប្បទានប័ត្រ លិខិតធ្វើការផ្ទេរ និង ឯកសារគាំទ្រនានា ដើម្បីធានាថា ព័ត៌មានទាំងអស់ ត្រឹមត្រូវគ្រប់គ្រាន់ និងពេញលេញ ហើយនិងការចំណាយត្រូវតាមច្បាប់ និង ស្របតាមផែនការ ។ | ប្រធានគណនេយ្យ | គណនេយ្យករ |

| | | |
|---|---|---|
| 16. ធ្វើការសម្រេចលើប័ណ្ណបញ្ចេញប្រាក់ មូលប្បទានប័ត្រ លិខិតផ្ទេរប្រាក់ និង ចុះហត្ថលេខា | ប្រធានអង្គភាព និង អ្នកមានសិទ្ធចុះហត្ថលេខា | ប្រធានមណ្ឌលសុខភាព និងអ្នកមានសិទ្ធិចុះហត្ថលេខា |
| 17. ក្រោយពីការសម្រេច ទាក់ទងអ្នកទទួលប្រាក់ ដើម្បីមកទទួលយកមូលប្បទានប័ត្រ ប្រសិនបើផ្ទេរតាមធនាគារ ត្រូវបញ្ជូនលិខិតផ្ទេរទៅធនាគារ ។<br>អ្នកទទួលប្រាក់ត្រូវបង្ហាញពីលិខិតស្នាមផ្លូវការ ដូចជាអត្តសញ្ញាណប័ណ្ណ ឬលិខិតផ្ទេរសិទ្ធពីក្រុមហ៊ុន ។ ត្រូវថតចម្លងលិខិតផ្លូវការនេះដោយភ្ជាប់ជាមួយច្បាប់ចម្លងនៃមូលប្បទានប័ត្រ ។<br>ផ្តល់មូលប្បទានប័ត្រដល់អ្នកទទួលប្រាក់ និងឲ្យគាត់ចុះហត្ថលេខាលើ ប័ណ្ណបញ្ចេញប្រាក់ ឬក៏វិក្កយបត្រផ្លូវការ ជាសក្ខីភាពនៃការទូទាត់។<br>បោះត្រា "PAID" លើច្បាប់ដើមនៃវិក្កយបត្រ និងឯកសារសំខាន់នានា ដែលនឹងប្រើប្រាស់ជាមូលដ្ឋានក្នុងការស្នើសុំប្រាក់បង្រ្គប់វិញភ្លាមៗ ដើម្បីជៀសវាងការទូទាត់ត្រួតគ្នា ។ | បេឡាករ | បេឡាករ |
| 18. ក្រោមពីទូទាត់ប្រាក់ កត់ត្រាព័ត៌មានលម្អិតអំពីប្រតិបត្តិការទៅក្នុងសៀវភៅធនាគារ (ឧបសម្ព័ន្ធទី ៥) ដើម្បីគ្រប់គ្រងសមតុល្យក្នុងធនាគារ និង រៀបចំការចំណាយតាមប្រភេទចំណាយ | គណនេយ្យករ | បេឡាករ |
| 19. ទុកឯកសារ ប័ណ្ណបញ្ចេញសាច់ប្រាក់ ជាមួយនឹងឯកសារគាំទ្រនានា ក្នុងសំណុំឯកសារទូទាត់តាមធនាគារ រៀបតាមលំដាប់លេខរៀង និង តាមខែ | គណនេយ្យករ | បេឡាករ |

## ៦.៣.៥ ការគ្រប់គ្រងបុរេប្រទាន

ថវិកាបុរេប្រទានអាចនឹងត្រូវទូទាត់ ដោយផ្អែកទៅលើផែនការថវិកាដែលបានអនុម័តសម្រាប់សកម្មភាពនីមួយៗ ។ អ្នកដែលធ្វើសំណើសុំបុរេថវិកា ត្រូវតែទទួលខុសត្រូវក្នុងការទូទាត់ថវិកាដែលបានបុរេប្រទាន (ថវិកាដែលបានស្នើសុំបម្រុងទុកមុនសម្រាប់ចំណាយ) ក្នុងអំឡុងពេល១០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានបំពេញសកម្មភាពចប់សព្វគ្រប់ ។ ថវិកាដែលនៅសេសសល់ ត្រូវបង្វិលត្រឡប់មកវិញ បន្ទាប់ពីបានទូទាត់ការចំណាយរួច ។ អាចនឹងមានការកាត់បន្ថយប្រាក់រង្វាន់ស្នាដៃការងារ សម្រាប់ថវិកាបុរេប្រទានណាមួយដែលមិនបានជម្រះបញ្ជីនៅក្នុងកំឡុងពេលវេលាកំណត់មួយ ឬ មិនបានផ្តល់ត្រឡប់វិញជាមួយនឹងការកែតម្រូវដែលអាចទទួលយកបានសម្រាប់ការជម្រះបញ្ជីចុងក្រោយ ។

### ៦.៣.៥.១ សំណើសុំប្រាក់បុរេប្រទាន

| និតិវិធី | មន្ទីរសុខាភិបាល/មន្ទីរពេទ្យខេត្ត/ស្រុកប្រតិបត្តិ/មន្ទីរពេទ្យបង្អែកស្រុក<br>អ្នកអនុវត្ត | មណ្ឌលសុខភាព<br>អ្នកអនុវត្ត |
|---|---|---|
| 1. បំពេញសំណើសុំបុរេប្រទាន (RA) (សូមមើលឧបសម្ព័ន្ធទី៩) ដើម្បីអនុវត្ត ការអនុម័តលើសកម្មភាព។ ចូរធ្វើការយោងទៅលើផែនការថវិកាដែលបានអនុម័ត នៅក្នុងសំណើសុំបុរេប្រទាននេះ (RA) ។ | អ្នកស្នើសុំ | អ្នកស្នើសុំ |
| 2. ពិនិត្យមើលសំណើសុំបុរេប្រទានដើម្បីធានាថាមានសុពលភាព ហើយចំនួនថវិកាគឺយោងតាមផែនការដែលបានអនុម័ត និងសមហេតុផល ។ | ប្រធានគណនេយ្យ | គណនេយ្យករ |
| 3. អនុម័តលើសំណើសុំបុរេប្រទាន (RA) ។ | ប្រធាន/នាយក | ប្រធានមណ្ឌលសុខភាព |

| | | |
|---|---|---|
| 4. ពេលដែលសំណើសុំបុរេប្រទានត្រូវបានអនុម័ត ធ្វើការទូទាត់បុរេប្រទានដោយយោងទៅលើ សេចក្តីណែនាំការចំណាយផ្នែកទី ៦.៣.៤ ។ | | |
| 5. នៅពេលដែលបានផ្តល់បុរេប្រទាន ត្រូវកត់ត្រាលម្អិតនៅក្នុងសៀវភៅបញ្ជីបុរេប្រទាន (សូមមើលឧបសម្ព័ន្ធទី១២) ដើម្បីត្រួតពិនិត្យសមតុល្យនៃបុរេប្រទាន និងការទូទាត់ដែលពាក់ព័ន្ធ ។ | គណនេយ្យករ | គណនេយ្យករ |

## ៦.៣.៥.២ ការជំរះថវិកាបុរេប្រទាន

| និតិវិធី | មន្ទីរសុខាភិបាល/មន្ទីរពេទ្យខេត្ត/ស្រុកប្រតិបត្តិ/មន្ទីរពេទ្យបង្អែកស្រុក<br>អ្នកអនុវត្ត | មណ្ឌលសុខភាព<br>អ្នកអនុវត្ត |
|---|---|---|
| 1. បំពេញសំណើសុំចំណាយ (សូមមើលឧបសម្ព័ន្ធទី១១) ដោយចុះក្នុងតារាងរាល់តម្លៃចំណាយ និងយោងលើវិក្កយបត្រ/ប័ណ្ណចំណាយនីមួយៗ និងឯកសារយោង ។ | អ្នកទទួលបានថវិកាបុរេប្រទាន | អ្នកទទួលបានថវិកាបុរេប្រទាន |
| 2. ពិនិត្យឡើងវិញរបាយការណ៍ចំណាយ និងរាល់ឯកសារគាំទ្រ ដើម្បីធានាថាការទូទាត់ការចំណាយត្រឹមត្រូវដោយបញ្ជាក់ថារាល់ការទូទាត់ មានឯកសារយោង និងមានសុពលភាព ឯកសារដើម ថវិកាបានអនុម័ត ។ ការងារគណនេយ្យសម្រាប់ការជម្រះបញ្ជីថវិកាបុរេប្រទាន មានដូចខាងក្រោម៖<br>• **នៅពេលដែលការចំណាយសរុបធំជាងចំនួនថវិកាបុរេប្រទាន** ត្រូវរៀបចំប័ណ្ណបញ្ចេញសាច់ប្រាក់ (DV) | ប្រធានគណនេយ្យ | គណនេយ្យករ |

| | | |
|---|---|---|
| ឬ វិក្កយបត្របង់ប្រាក់ (PCPV) ដើម្បីធ្វើការទូទាត់តាមធនាគារ ឬ ថវិការជ្ជទេយ្យ ។ ការងារគណនេយ្យត្រូវបញ្ចូលមានៈ<br>ឥណពន្ធៈ គណនីចំណាយ xxxx<br>ឥណទានៈ គណនីធនាគារ/ថវិការជ្ជទេយ្យ xxxx<br>ឥណទានៈ គណនីបុរេប្រទាន xxxx<br>• **នៅពេលដែលការចំណាយសរុបតិចជាងចំនួនថវិកាបុរេប្រទាន** ត្រូវចេញប័ណ្ណបង់ប្រាក់ជាផ្លូវការ (សូមមើលឧបសម្ព័ន្ធទី១៣) ដើម្បីសងប្រាក់ដែលបានបុរេ នៅសល់ត្រឡប់មកវិញ ។ ប្រសិនបើថវិកាដែលត្រូវសងត្រឡប់មិនលើសពីចំនួនដែនកំណត់នៃថវិការជ្ជទេយ្យទេ គឺអាចរក្សាវាទុកក្នុងថវិការជ្ជទេយ្យនោះ ។ បើមិនដូច្នោះទេ គឺត្រូវតម្កល់វាទៅក្នុងធនាគារ ។ ការងារគណនេយ្យត្រូវបញ្ចូលមានៈ<br>ឥណពន្ធៈ គណនីចំណាយ xxxx<br>ឥណពន្ធៈ គណនីធនាគារ/ថវិការជ្ជទេយ្យ xxxx<br>ឥណទានៈ គណនីបុរេប្រទាន xxxx<br><br>• **នៅពេលដែលការចំណាយសរុបស្មើចំនួនថវិកាបុរេប្រទាន** ត្រូវរៀបចំសៀវភៅវិក្កយបត្រ (Journal Voucher) (សូមមើលឧបសម្ព័ន្ធទី៤) ដើម្បីទូទាត់ប្រាក់ដែលបានបុរេ។ការងារគណនេយ្យត្រូវបញ្ចូលមានៈ<br>ឥណពន្ធៈ គណនីចំណាយ xxxx<br>ឥណទានៈ គណនីបុរេប្រទាន xxxx | | |

| | | | |
|---|---|---|---|
| 3. | របាយការណ៍អនុម័តការចំណាយ និងវិក្កយបត្រទទួលផ្លូវការដែលពាក់ព័ន្ធ ប័ណ្ណបញ្ចេញសាច់ប្រាក់ (DV) វិក្កយបត្របង់ប្រាក់ (PCPV) | ប្រធាន/នាយក | ប្រធានមណ្ឌលសុខភាព |
| 4. | នៅពេលដែលសាច់ប្រាក់ត្រូវបានដាក់នៅក្នុងរជ្ជទេយ្យ បេឡាករត្រូវចុះហត្ថលេខាលើវិក្កយបត្រទទួលផ្លូវការ និងកត់ត្រាចូលក្នុងសៀវភៅបញ្ជីរជ្ជទេយ្យ ។<br><br>នៅពេលដែលសាច់ប្រាក់ត្រូវបានដាក់បញ្ចូលនៅធនាគារ ត្រូវអនុវត្តតាមនិតិវិធីស្តីពីវិក្កយបត្រផ្លូវការ (សូមមើលផ្នែក៦.៣.៣) សម្រាប់កិច្ចបញ្ជីការគណនេយ្យ ប្រាក់សងត្រឡប់ ។ | បេឡាករ<br><br>គណនេយ្យករ | បេឡាករ<br><br>បេឡាករ |
| 5. | កត់ត្រាលម្អិតនូវការជម្រះបញ្ជីថវិកាបុរេក្នុងសៀវភៅបញ្ជីបុរេមួយ (សូមមើលនៅក្នុងឧបសម្ព័ន្ធ ១២) ដើម្បីត្រួតពិនិត្យការទូទាត់ដែលពាក់ព័ន្ធ ។ | គណនេយ្យករ | គណនេយ្យករ |

### ៦.៣.៥.៣ ការសម្របសម្រួលថវិកាបុរេប្រទាន

នៅចុងបញ្ចប់នៃខែ គ្រប់ថវិកាបុរេប្រទានទាំងអស់ដែលបានចុះក្នុងតារាងនៃបញ្ជីបុរេថវិកា ត្រូវបូកបញ្ចូលគ្នា ។ តុល្យការនៃថវិកានៅក្នុងបញ្ជីថវិកាបុរេ សរុបទាំងអស់ ត្រូវដូចគ្នាទៅនឹងចំនួនដែលបានកត់ត្រាក្នុងសៀវភៅបញ្ជីនោះ ។

### ៦.៣.៦ ការត្រួតពិនិត្យសារពើភ័ណ្ឌ

នៅពេលដែលចំនួននៃការផ្គត់ផ្គង់/សម្ភារៈធំ ត្រូវបានទិញសម្រាប់ប្រើប្រាស់ ក្នុងរយៈពេលយូរជាងមួយខែ ចាំបាច់ត្រូវមានការត្រួតពិនិត្យបន្ថែមលើការទិញបែបនេះ ដើម្បីជៀសវាងការប្រើប្រាស់ខុស ឬមិនត្រឹមត្រូវ ឬ ការបាត់បង់ ។ ការទិញសម្ភារៈ និង ការផ្គត់ផ្គង់ភាគច្រើន ត្រូវរក្សាទុកក្នុងទូរចាក់សោក្រោមការថែរក្សាពីបុគ្គលិកណាម្នាក់នៃអង្គភាព ។

## ៦.៣.៦.១ ការបញ្ចូលស្តុក

| និតិវិធី | មន្ទីរសុខាភិបាល/មន្ទីរពេទ្យខេត្ត/ស្រុកប្រតិបត្តិ/មន្ទីរពេទ្យបង្អែកស្រុក<br>អ្នកអនុវត្ត | មណ្ឌលសុខភាព<br>អ្នកអនុវត្ត |
|---|---|---|
| 1. នៅពេលទទួលបានការផ្គត់ផ្គង់ និងបានដាក់ចូលទៅក្នុងឃ្លាំង ត្រូវរៀបចំវិក្កយបត្របញ្ចូលស្តុក (សូមមើលឧបសម្ព័ន្ធទី២៧) និងភ្ជាប់ជាមួយច្បាប់ចម្លងនៃរបាយការណ៍ទទួលមួយច្បាប់ (សូមមើលឧបសម្ព័ន្ធទី២៦) ឬឯកសារផ្គត់ផ្គង់ទំនិញ ។ | អ្នកថែរក្សា | អ្នកថែរក្សា |
| 2. វិក្កយបត្របញ្ចូលស្តុក ត្រូវពិនិត្យឡើងវិញដើម្បីធានាថាវាមានភាពពេញលេញ និងព័ត៌មានត្រឹមត្រូវ ។ | ប្រធានគណនេយ្យ | គណនេយ្យករ |
| 3. ចុងក្រោយ គឺវាត្រូវបានអនុម័ត | ប្រធានអង្គភាព | ប្រធានមណ្ឌលសុខភាព |
| 4. បន្ទាប់ពីការអនុម័ត ត្រូវកត់ត្រាព័ត៌មានលម្អិតរបស់ស្តុកដែលបានទទួល ទៅក្នុងបញ្ជីត្រួតពិនិត្យស្តុក (សូមមើលឧបសម្ព័ន្ធទី២៩) ។ | អ្នកថែរក្សា | អ្នកថែរក្សា |

## ការបញ្ចេញពីស្តុក

| និតិវិធី | មន្ទីរសុខាភិបាល/ មន្ទីរពេទ្យខេត្ត/ ស្រុកប្រតិបត្តិ/មន្ទីរពេទ្យបង្អែកស្រុក<br>អ្នកអនុវត្ត | មណ្ឌលសុខភាព<br>អ្នកអនុវត្ត |
|---|---|---|
| 1. អ្នកដែលត្រូវការសម្ភារៈ ត្រូវរៀបចំវិក្កយបត្របញ្ចេញស្តុក (សូមមើលឧបសម្ព័ន្ធទី២៨) ។ | អ្នកស្នើសុំ | អ្នកស្នើសុំ |
| 2. ត្រូវត្រួតពិនិត្យវិក្កយបត្របញ្ចេញស្តុកឡើងវិញដើម្បីបញ្ជាក់ថា តម្រូវការនៃសម្ភារៈដែលបានស្នើសុំពិតជាត្រឹមត្រូវ ។ | អ្នកអភិបាលផ្ទាល់ | អ្នកអភិបាលផ្ទាល់ |
| 3. ចុងក្រោយ គឺវាត្រូវបានអនុម័ត | ប្រធានអង្គភាព | ប្រធានមណ្ឌលសុខភាព |
| 4. នៅពេលមានការអនុម័ត មុខទំនិញត្រូវបញ្ចេញជូនដល់អ្នកដែលបានស្នើសុំ ដែលនឹងត្រូវចុះហត្ថលេខាទទួលស្គាល់លើការទទួលបានទំនិញ។ | អ្នកថែរក្សា | អ្នកថែរក្សា |
| 5. ក្រោយពេលអនុម័ត ត្រូវកត់ត្រាព័ត៌មានលម្អិតអំពីស្តុកដែលបានបញ្ចេញ នៅក្នុងបញ្ជីត្រួតពិនិត្យស្តុក (សូមមើលឧបសម្ព័ន្ធទី២៩) ។ | អ្នកថែរក្សា | អ្នកថែរក្សា |

## ៦.៣.៦.២ ការរាប់ចំនួន និងការទូទាត់បញ្ជី

នៅរៀងរាល់ត្រីមាសនីមួយៗ ការរាប់ជាក់ស្តែងនូវមុខទំនិញនៅក្នុងឃ្លាំងនឹងត្រូវធ្វើឡើងដោយបុគ្គលផ្សេងដែលមិនពាក់ព័ន្ធក្នុងការថែរក្សាឃ្លាំងផ្គត់ផ្គង់ ។ លទ្ធផលនៃការរាប់ ត្រូវតែដូចគ្នាជាមួយនឹងបរិមាណដែលមាននៅក្នុងសៀវភៅត្រួតពិនិត្យសម្ភារៈផ្គត់ផ្គង់នេះ ។ ភាពខុសគ្នាណាមួយ ត្រូវតែស៊ើបអង្កេត និងកែតម្រូវតាមស្ថានភាពនោះ ។ របាយការណ៍ស្តីពីលទ្ធផលលម្អិតពីការរាប់ចំនួន នេះ

ត្រូវតែរៀបចំដោយអ្នកដែលអនុវត្តការរាប់នោះ ហើយត្រូវវានត្រួតពិនិត្យឡើងវិញ និង អនុម័តដោយ គណនេយ្យករ និងប្រធានមណ្ឌលសុខភាពរៀងខ្លួនសម្រាប់ថ្នាក់មណ្ឌលសុខភាព និងដោយប្រធាន គណនេយ្យ និងប្រធានស្ថាប័នសម្រាប់ មន្ទីរសុខាភិបាល សម្រាប់ការិយាល័យស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកខេត្ត និងមន្ទីរពេទ្យបង្អែក ។

## ៦.៤ អចលនទ្រព្យ

សម្ភារៈ និង ទំនិញ ដែលបានទិញ (ប្រសិនបើមាន) ដោយប្រើប្រាស់ថវិកាជំនួយដែលទទួលបាន ត្រូវតែកត់ត្រានិងទទួលខុសត្រូវការប្រើប្រាស់ដូចនៅក្នុងប្រព័ន្ធធម្មតារបស់រាជរដ្ឋាភិបាលដែរ ។

ផ្នែកបន្តបន្ទាប់ដូចខាងក្រោមនេះ អាចអនុវត្តសម្រាប់ការគ្រប់គ្រងសម្ភារៈ និងទំនិញដែលបានទិញដោយគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល និងបានផ្តល់ទៅឱ្យមូលដ្ឋានសុខាភិបាល ការិយាល័យស្រុកប្រតិបត្តិ ឬ មន្ទីរសុខាភិបាលខេត្ត ។

### ៦.៤.១ ការចុះបញ្ជីអចលនទ្រព្យ

សម្ភារៈនិងទំនិញ ត្រូវកត់ត្រាដូចការចំណាយនានាដែរនៅពេលដែលទិញ ។ ដើម្បីត្រួតពិនិត្យការទិញ ត្រូវរក្សាទុកបញ្ជីទ្រព្យសម្បត្តិ (ឧបសម្ព័ន្ធទី១៤) ដើម្បីត្រួតពិនិត្យមុខទំនិញដែលមានអាយុកាលប្រើប្រាស់**ច្រើនជាងមួយឆ្នាំ** និងមានតម្លៃចាប់ពី ៤០០,០០០រៀល ឬលើសពីនេះ ។ មុខទំនិញដែលមានតម្លៃក្រោមនេះ ត្រូវចាត់ទុកជាសម្ភារៈសម្រាប់ប្រើប្រាស់ ។ សម្ភារៈណាមួយដែលបានផ្តល់ទៅអង្គភាពប្រតិបត្តិដោយក្រសួងសុខាភិបាលនៅក្រោមគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល នឹងត្រូវរក្សាទុកនៅក្នុងបញ្ជីទ្រព្យសម្បត្តិ ដោយគណនេយ្យករ ។ ទ្រព្យសម្បត្តិនីមួយៗ ត្រូវកំណត់អត្តសញ្ញាណ លេខកូដ ក្នុងគោលបំណងដើម្បីបង្កើតភាពជាម្ចាស់ និងការទទួលខុសត្រូវ ។ ចំពោះ ទ្រព្យសម្ភារៈ ដែលបានទិញនៅក្រោមគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល (ប្រសិនបើមាន) នាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ នឹងផ្តល់តែមសារពើភ័ណ្ឌសម្រាប់បិទលើទ្រព្យសម្បត្តិនីមួយៗ ។ គណនេយ្យករនៃអង្គភាពនីមួយៗត្រូវប្រាកដថា តែមសារពើភ័ណ្ឌដែលបានផ្តល់ដោយនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ ត្រូវបានបិទភ្ជាប់ទៅនឹងទ្រព្យសម្បត្តិនីមួយៗ ។ តែមសារពើភ័ណ្ឌណាមួយដែលបានបាត់បង់ ត្រូវរកតែមថ្មីមកជំនួសវិញភ្លាម ។

### ៦.៤.២ ការរាប់អចលនទ្រព្យ ជាក់ស្តែង

ការរាប់អចលនទ្រព្យជាក់ស្តែង ត្រូវធ្វើឡើងយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ អាស្រ័យលើបរិមាណនៃទ្រព្យសម្បត្តិ និង ចលនាក្នុងអំឡុងពេលនៃឆ្នាំ ។ នៅមុនចុងបញ្ចប់នៃឆ្នាំ អង្គភាពនីមួយៗ ត្រូវតែអនុវត្តការរាប់ជាក់ស្តែងនូវ ទ្រព្យ សម្ភារៈ ក្នុងគោលបំណងដើម្បីធានាថាទ្រព្យសម្បត្តិទាំងអស់ មានកំណត់ហេតុត្រឹមត្រូវ និងដើម្បីកំណត់ការខូចខាត ឬការបាត់បង់ណាមួយ ។

ដើម្បីអនុវត្តការរាប់នេះ គណនេយ្យករត្រូវបោះពុម្ពចេញនូវបញ្ជី ទ្រព្យ សម្ភារៈ និងធ្វើការរាប់ជាក់ស្តែងធៀបទៅនឹងបញ្ជី ។

រាល់ការបាត់បង់ ខូចខាត ឬ ឈប់ប្រើ ត្រូវកំណត់ និងរាយការណ៍ទៅក្នុងរបាយការណ៍សង្ខេបនៃ ទ្រព្យ សម្ភារៈ ដែលបានរាប់ជាក់ស្តែង ដែលត្រូវចុះហត្ថលេខាដោយអ្នកពាក់ព័ន្ធនឹងការរាប់ និងត្រូវអនុម័តដោយអ្នកគ្រប់គ្រង អង្គភាពនីមួយៗ។

រាល់ការបាត់បង់ ខូចខាត ឬ ឈប់ប្រើ ត្រូវកំណត់ និងរាយការណ៍ទៅថ្នាក់គ្រប់គ្រងជាបន្ទាន់ ។ លុះណាតែមានការយល់ព្រមពីក្រសួងសុខាភិបាលតែប៉ុណ្ណោះ ទើបអាចធ្វើការកែតម្រូវលើកំណត់ត្រាគណនេយ្យ និងបញ្ជីទ្រព្យសម្បត្តិ ។

### ៦.៤.៣ ការទុកដាក់ឯកសារ

បញ្ជីអចលនទ្រព្យ មានការរាប់គូសសម្គាល់ និងរបាយការណ៍សង្ខេបនៃការរាប់ជាក់ស្តែង ត្រូវបានរក្សាទុកក្នុងទូររក្សាឯកសារ ។

### ៦.៥ ការថែទាំកំណត់ត្រាហិរញ្ញវត្ថុ

រាល់កំណត់ត្រាគណនេយ្យ និងហិរញ្ញវត្ថុសម្រាប់កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល និងថវិកាផ្សារភ្ជាប់ស្នាដៃការងារ ត្រូវរក្សាទុកដោយអង្គភាពប្រតិបត្តិនីមួយៗក្នុងទូរដែលមានសោសុវត្ថិភាព ដែលការចូលប្រើប្រាស់ត្រូវរឹតត្បិត គឺសម្រាប់តែអ្នកមានសិទ្ធប្រើប្រាស់តែប៉ុណ្ណោះ ។

## ៦.៦ របាយការណ៍ហិរញ្ញវត្ថុ

### ៦.៦.១ របាយការណ៍ហិរញ្ញវត្ថុប្រចាំខែ

*របាយការណ៍ហិរញ្ញវត្ថុប្រចាំខែ*

| ដំណើរការ | មន្ទីរសុខាភិបាល/ មន្ទីរពេទ្យខេត្ត/ស្រុកប្រតិបត្តិ/មន្ទីរពេទ្យបង្អែកស្រុក<br>អនុវត្តដោយ: | មណ្ឌលសុខភាព អនុវត្តដោយ: |
|---|---|---|
| 1. ព័ត៌មានពីសៀវភៅធនាគារ សៀវភៅបញ្ជីរដ្ឋទេយ្យ និងសៀវភៅបញ្ជីបុរេប្រទាន នឹងត្រូវទាញចេញដើម្បីធ្វើសេចក្ដីប្រកាសពីចំណូលចំណាយ និងតុល្យការថវិកា (ឧបសម្ព័ន្ធទី២០) | គណនេយ្យករ | បេឡាករ |
| 2. សេចក្ដីប្រកាសប្រចាំខែពីចំណូលចំណាយ និងតុល្យការថវិកា នឹងត្រូវត្រួតពិនិត្យឡើងវិញដើម្បីបញ្ជាក់ពីភាពពេញលេញ និងព័ត៌មានត្រឹមត្រូវ ។ ការពិនិត្យឡើងវិញនឹងត្រូវពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានក្នុងសេចក្ដីប្រកាស ជាមួយនឹងព័ត៌មាននៅក្នុងសៀវភៅធនាគារ បញ្ជីរដ្ឋទេយ្យ និងបញ្ជីបុរេប្រទាន ។ បញ្ហាមិនបានគិតដល់ ឬ ទំនាស់ព័ត៌មានណាមួយត្រូវតែស៊ើបអង្កេតនិងកែតម្រូវទៅតាមស្ថានភាពជាក់ស្ដែង ។ | ប្រធានគណនេយ្យ | គណនេយ្យករ |
| 3. ជាចុងក្រោយ ការអនុម័តលើសេចក្ដីប្រកាសនេះនឹងត្រូវបានធ្វើឡើង មិនឲ្យលើសពីថ្ងៃទី៧នៃខែបន្ទាប់។ | ប្រធានអង្គភាព | ប្រធានមណ្ឌលសុខភាព |

## ៦.៦.២ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស

### ៦.៦.២.១ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសនៃអង្គភាពប្រតិបត្តិនីមួយៗ

| និតិវិធី | មន្ទីរសុខាភិបាល/ មន្ទីរពេទ្យខេត្ត/ ស្រុកប្រតិបត្តិ/មន្ទីរពេទ្យបង្អែកស្រុក អនុវត្តដោយ: | មណ្ឌលសុខភាព អនុវត្តដោយ: |
|---|---|---|
| 1. ផ្អែកលើព័ត៌មានពីសេចក្តីប្រកាស ពីចំណូល ចំណាយ និងតុល្យការថវិកា សេចក្តីប្រកាសប្រចាំត្រីមាសនៃវិក្កយបត្រ និងរបាយការណ៍ចំណាយ (ឧបសម្ព័ន្ធទី ២១) ត្រូវបានរៀបចំ ។ | គណនេយ្យករ | បេឡាករ |
| 2. សេចក្តីប្រកាសប្រចាំត្រីមាសពីចំណូលចំណាយ ត្រូវពិនិត្យនិងជានាពីភាពពេញលេញនិងភាពត្រឹមត្រូវនៃព័ត៌មាន ។ អ្នកត្រួតពិនិត្យ គួរផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុងសេចក្តីប្រកាសជាមួយព័ត៌មាននៅក្នុងសេចក្តីប្រកាសប្រចាំខែពីចំណូលចំណាយ និងតុល្យការថវិកា ។ | ប្រធានគណនេយ្យ | គណនេយ្យករ |
| 3. ជាចុងក្រោយ ការអនុម័តលើសេចក្តីប្រកាសនេះនឹងត្រូវបានធ្វើឡើង មិនឲ្យលើសពីថ្ងៃទី៧នៃខែបន្ទាប់ឡើយ ។ | ប្រធានអង្គភាព | ប្រធានមណ្ឌលសុខភាព |

មណ្ឌលសុខភាព និងមន្ទីរពេទ្យត្រូវផ្ញើសេចក្តីប្រកាស ចំណូលចំណាយប្រចាំត្រីមាសថតចម្លងមួយច្បាប់ទៅស្រុកប្រតិបត្តិមិនឲ្យលើកពី១០ថ្ងៃបន្ទាប់ពីចុងបញ្ចប់ត្រីមាសនីមួយៗ សម្រាប់ការបូកសរុប លើកលែងតែសេចក្តីប្រកាសប្រចាំត្រីមាសទី៤ នៃចំណូលនិងចំណាយ ដែលត្រូវដាក់ជូនទៅការិយាល័យសុខាភិបាលស្រុកប្រតិបត្តិនៅថ្ងៃទី៣១ ខែធ្នូ សម្រាប់ការបូកសរុប ។

មន្ទីរពេទ្យខេត្តត្រូវផ្ញើច្បាប់ចម្លងនៃសេចក្តីប្រកាសមួយច្បាប់ប្រចាំត្រីមាស នៃចំណូលនិងចំណាយទៅមន្ទីរសុខាភិបាលខេត្តមិនឲ្យលើសពី១០ថ្ងៃបន្ទាប់ពីចុងត្រីមាសនីមួយៗ សម្រាប់ការបូកសរុប លើកលែងតែសេចក្តីប្រកាសប្រចាំត្រីមាសទី៤នៃចំណូលនិងចំណាយដែលត្រូវបានដាក់ជូនទៅមន្ទីរសុខាភិបាលនៅថ្ងៃទី៣១ ខែធ្នូ សម្រាប់ការបូកសរុប ។

ស្រុកប្រតិបត្តិ ត្រូវរៀបចំឯកសារប្រចាំត្រីមាសបូកសរុប សម្រាប់ការិយាល័យស្រុកប្រតិបត្តិ មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកស្រុក ។

### ៦.៦.២.២ ស្រុកប្រតិបត្តិ រៀបចំរបាយការណ៍ហិរញ្ញវត្ថុបូកសរុបប្រចាំត្រីមាសរបស់ការិយាល័យស្រុកប្រតិបត្តិ មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកស្រុក

បន្ទាប់ពីទទួលបាន សេចក្តីប្រកាសចំណូលនិងចំណាយប្រចាំត្រីមាសពីមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក គណនេយ្យករស្រុកប្រតិបត្តិ ត្រូវពិនិត្យសេចក្តីប្រកាសទាំងនោះ ហើយរៀបចំរបាយការណ៍សេចក្តីប្រកាសចំណូលចំណាយប្រចាំត្រីមាសរួម (ឧបសម្ព័ន្ធទី២២) សម្រាប់មណ្ឌលសុខភាពទាំងអស់ និងមន្ទីរពេទ្យបង្អែកដែលស្ថិតនៅក្រោមការិយាល័យស្រុកប្រតិបត្តិ ។ សេចក្តីប្រកាស ចំណូលចំណាយរួមប្រចាំត្រីមាស ត្រូវត្រួតពិនិត្យមើលឡើងវិញដោយប្រធានគណនេយ្យនៃស្រុកប្រតិបត្តិ និងបន្ទាប់មកត្រូវអនុម័តដោយប្រធានការិយាល័យស្រុកប្រតិបត្តិ។

ស្រុកប្រតិបត្តិត្រូវផ្ញើរបាយការណ៍ចំណូលចំណាយសរុបប្រចាំត្រីមាស ទៅមន្ទីរសុខាភិបាលខេត្តមិនឲ្យលើសពី១៥ថ្ងៃ បន្ទាប់ពីចុងបញ្ចប់នៃត្រីមាសដើម្បីបូកសរុបរបាយការណ៍ លើកលែងតែសេចក្តីប្រកាសចំណូលចំណាយសម្រាប់ត្រីមាសទី៤ ដែលនឹងត្រូវដាក់ជូននៅថ្ងៃទី៥ ខែមករានៃឆ្នាំបន្ទាប់ ។

### ៦.៦.២.៣ មន្ទីរសុខាភិបាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួមប្រចាំត្រីមាសរបស់មន្ទីរសុខាភិបាល មន្ទីរពេទ្យខេត្ត ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព

បន្ទាប់ពីទទួលបានរបាយការណ៍ចំណូលចំណាយរួមប្រចាំត្រីមាសពី ការិយាល័យស្រុកប្រតិបត្តិ និងមន្ទីរពេទ្យខេត្ត គណនេយ្យករមន្ទីរសុខាភិបាលនឹងពិនិត្យមើលភាពត្រឹមត្រូវ និងភាពពេញលេញនៃព័ត៌មានហិរញ្ញវត្ថុនៅក្នុងសេចក្តីប្រកាសនោះ រួចបង្កើតជាសេចក្តីប្រកាសចំណូលចំណាយរួមប្រចាំត្រីមាស (ឧបសម្ព័ន្ធទី២៣) សម្រាប់អង្គភាពប្រតិបត្តិទាំងមូល ។ សេចក្តីប្រកាសរួមនេះ ត្រូវត្រួតពិនិត្យឡើងវិញដោយប្រធានគណនេយ្យនៃមន្ទីរសុខាភិបាល ដើម្បីពិនិត្យមើលភាពពេញលេញ និងភាពត្រឹមត្រូវនៃព័ត៌មាន និងបន្ទាប់មកត្រូវអនុម័តដោយប្រធានមន្ទីរសុខាភិបាលខេត្ត។

មន្ទីរសុខាភិបាលត្រូវបញ្ជូនសេចក្តីប្រកាសចំណូលចំណាយរួមប្រចាំត្រីមាសនៃអង្គភាពប្រតិបត្តិទាំងអស់ទៅក្រសួងសុខាភិបាល មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត និងរតនាគារខេត្តមិនឲ្យលើសពី២៥ ថ្ងៃ បន្ទាប់ពីចុងបញ្ចប់នៃត្រីមាសនីមួយៗ លើកលែងតែសេចក្តីប្រកាសរួមនៃត្រីមាសទី៤ ដែលត្រូវដាក់នៅថ្ងៃទី១០ ខែមករា នៃឆ្នាំបន្ទាប់ ។

### ៦.៦.៣ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស និងប្រចាំឆ្នាំ

ដំណើរការ និងនិតិវិធីសម្រាប់ការរៀបចំរបាយការណ៍ប្រចាំឆមាស និងឆ្នាំ ដូចគ្នាជាមួយនឹងដំណើរការ និងនិតិវិធីសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទាំងនោះដែរ ។ ទម្រង់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស និងឆ្នាំ មាននៅក្នុងឧបសម្ព័ន្ធទី២៤ ។

### ៦.៧ សវនកម្ម

### ៦.៧.១ លក្ខណៈវិនិច្ឆ័យសម្រាប់ទទួលថវិកាផ្សារភ្ជាប់ស្នាដៃការងារ

ការអនុវត្ត ប្រភេទកញ្ចប់ថវិកាសម្រាប់ប្រតិបត្តការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល និងថវិកាផ្សារភ្ជាប់ស្នាដៃការងារ គឺជាប្រធានបទនៃសវនកម្មផ្ទៃក្នុងជម្មតាដែលធ្វើឡើងដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសុខាភិបាល ។

### ៦.៧.២ សវនកម្មខាងក្រៅ

